# ព្រឹទ្ធសភា

# SENATE MAGAZINE

ទស្សនាវដ្ដីប្រចាំខែកញ្ញា



លេខ ២៦៣ ឆ្នាំទី២២
ពុទ្ធសករាជ ២៥៦៦ គ្រិស្តសករាជ ២០២២

Issue 263 Volume 22
Before Christ 2566 Common Era 2022

# មាតិកា


## សកម្មភាពថ្នាក់ដឹកនាំ



- សម្តេចប្រមុខរដ្ឋស្តីទីទទួលជួបឯកអគ្គរដ្ឋទូតតួកគី ........................ ១
- សម្តេចប្រមុខរដ្ឋស្តីទីអនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ ចូលជូនសារតាំង និងសម្តែងការគួរសម ........................ ៣
- សម្តេចប្រមុខរដ្ឋស្តីទីអនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតក្វាតេម៉ាឡា ចូលជូនសារតាំង ........................ ៥
- សម្តេចប្រមុខរដ្ឋស្តីទីអនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតបេឡារុស ចូលជូនសារតាំង ........................ ៧
- ព្រឹទ្ធសភាកាន់បិណ្ឌវេនទី១៤ នៅវត្តបទុមវត្តីរាជវរារាម ........................ ៩
- ព្រឹទ្ធសភារៀបចំពិធីសម្ពោធស្លាកសមិទ្ធផលជំនួយរបស់ស្ថានទូតចិនប្រចាំកម្ពុជា ........................ ១១
- ថ្នាក់ដឹកនាំព្រឹទ្ធសភាសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ........................ ១៤

## សកម្មភាពគណៈកម្មការ

- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ........................ ១៥
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨ ........................ ១៧
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ........................ ៣១
- ការងារទទួលពាក្យបណ្តឹង ........................ ៣៣

## សកម្មភាពអគ្គលេខាធិការដ្ឋាន



- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែសីហា និងកំណត់ទិសដៅការងារខែកញ្ញា ឆ្នាំ២០២២ ........................ ៣៤
- ថ្នាក់ដឹកនាំអង្គភាពចំណុះ អ.ពស ត្រូវបានពង្រឹងសមត្ថភាពលើជំនាញការគ្រប់គ្រងធនធានមនុស្ស ........................ ៣៥
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភារៀបចំពិធីបរិច្ចាគឈាម ........................ ៣៦
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ........................ ៣៧



**អ្នកគ្រប់គ្រងទូទៅ**
ឯកឧត្តម អ៊ុំ សារិទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**
ឯកឧត្តម លឹម ប៊ុនហុក
ឯកឧត្តម កែវ ចាន់ណា
ឯកឧត្តម សុខ រិទ្ធី
ឯកឧត្តម ជួន ណា
ឯកឧត្តម គឹម ពិសិដ្ឋ
លោក ជួន សុខធី
លោក ទេព មករា
លោក កុក វ៉ៃ

**អ្នកគ្រប់គ្រងផ្ទាល់**
លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**
ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**
លោក ជុំ ច័ន្ទរតនា
កញ្ញា សុខ សុជាតា


*ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ អញ្ជើញប្រារព្ធពិធីបង្សុកូល ឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធមាតា បិតា និងញាតិកាទាំង៧សន្តាន នៅឃុំកោះសូទិន ខេត្តកំពង់ចាម។*

*ក្របក្រោយ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ នៅឃុំកោះសូទិន ខេត្តកំពង់ចាម៕*


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
**ទូរស័ព្ទ: (855) 23 211441, 211442, 211443, ទូរសារ: (855) 23 211446**
**E-mail : oumsarith.sgsenate@gmail.com**
**Website: www.senate.gov.kh**
**www.elibrary.senate.gov.kh**
**Facebook: www.facebook.com/senateofcambodia**

# សម្តេចប្រមុខរដ្ឋស្តីទីទទួលជួបឯកអគ្គរដ្ឋទូតតួកគី



*លោកជំទាវ UIKU Kocaefe និងសម្តេចវិបុលសេនាភក្តី សាយ ឈុំ*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង៩:០០នាទី សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យលោកជំទាវ UIKU Kocaefe ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋតួកគី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។

ក្នុងព្រះបរមនាមព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានសម្តែងអំណរសាទរស្វាគមន៍ចំពោះលោកជំទាវ UIKU Kocaefe ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋតួកគីប្រចាំព្រះរាជាណាចក្រកម្ពុជា។ តាមរយៈបេសកកម្មការទូតរបស់លោកជំទាវ សម្តេចមានជំនឿជឿជាក់ថា លោកជំទាវនឹងខិតខំបន្តពង្រឹងពង្រីកនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីជាគុណប្រយោជន៍ដ៏ធំធេងទាំងពេលបច្ចុប្បន្ន និងពេលអនាគត។

នៅក្នុងឱកាសនោះ លោកជំទាវឯកអគ្គរដ្ឋទូតបានសម្តែងនូវការពេញចិត្ត និងវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងប្រទេសទាំងពីរ លើវិស័យនយោបាយ ពាណិជ្ជកម្ម ការវិនិយោគ និងវិស័យអប់រំ។

លោកជំទាវឯកអគ្គរដ្ឋទូត បានជម្រាបជូនសម្តេចប្រមុខរដ្ឋស្តីទីជ្រាបថា សភាតួកគីបានបង្កើតក្រុមមិត្តភាពជាមួយនឹងសភា នៃព្រះរាជាណាចក្រកម្ពុជា។ លោកជំទាវមាន



*ទិដ្ឋភាពក្នុងពិធីចូលជូនសារតាំង*

ជំនឿថា នឹងមានការផ្លាស់ប្ដូរគណៈប្រតិភូកម្រិតខ្ពស់រវាងសភា នៃប្រទេសទាំងពីរ ដើម្បីជំរុញការយល់ដឹងរួមគ្នា និងបង្កើននូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែខ្លាំងក្លាថែមទៀត។ ជាមួយគ្នានោះ លោកជំទាវបានវាយតម្លៃខ្ពស់ចំពោះសារៈសំខាន់របស់ប្រទេសកម្ពុជានៅក្នុងតំបន់អាស៊ី។

លោកជំទាវឯកអគ្គរដ្ឋទូតបានសម្ដែងនូវការអបអរសាទរចំពោះប្រទេសកម្ពុជាក្នុងតួនាទីជាប្រធានអាស៊ានប្ដូរវេន ដែលជាដំណាក់កាលដ៏លំបាកក្នុងការដោះស្រាយបញ្ហាក្នុងតំបន់ និងលើសកលលោក។ ទោះបីជាយ៉ាងនេះក្ដី ក៏ប្រទេសកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ និងទទួលបានលទ្ធផលប្រកបដោយជោគជ័យ។

សម្ដេចប្រមុខរដ្ឋស្ដីទីបានរំលឹកអំពីទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ ដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៥៩ និងការបើកសម្ពោធជាផ្លូវការស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅសាធារណរដ្ឋតួកគី កាលពីខែកុម្ភៈ ឆ្នាំ២០២២ កន្លងទៅ។ តាមរយៈទំនាក់ទំនងការទូតនៃប្រទេសទាំងពីរ សម្ដេចបានសម្ដែងនូវសេចក្ដីពេញចិត្ត និងវាយតម្លៃខ្ពស់ចំពោះចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រជាជន និងប្រទេសទាំងពីរ ដែលមានការរីកចម្រើនឥតឈប់ឈរ។

ក្នុងនាមប្រជាជនកម្ពុជា និងក្នុងនាមសម្ដេចផ្ទាល់ សម្ដេចបានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលតួកគីបានរួមចំណែកដ៏ថ្លៃថ្លាជួយអភិវឌ្ឍលើគ្រប់វិស័យ ដែលធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាមានការរីកចម្រើនខាងសង្គម សេដ្ឋកិច្ចដូចពេលបច្ចុប្បន្ន។ ជាមួយគ្នានោះ សម្ដេចបានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលតួកគីដែលបានគាំទ្រកម្ពុជាក្នុងតួនាទីជាប្រធានអាស៊ានប្ដូរវេន និងបានអញ្ជើញចូលរួមកិច្ចប្រជុំត្រីភាគី (កម្ពុជា-តួកគី និងលេខាធិការដ្ឋានអាស៊ាន) អាស៊ាន-តួកគីលើកទី៤ នៅរាជធានីភ្នំពេញ ក្នុងឱកាសកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ និងកិច្ចប្រជុំពាក់ព័ន្ធកាលពីថ្ងៃទី៣ ដល់ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ កន្លងទៅ។

សម្ដេចប្រមុខរដ្ឋស្ដីទីបានបញ្ជាក់ថា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នជាតិ នៃព្រះរាជាណាចក្រកម្ពុជាត្រៀមខ្លួនជានិច្ច ដើម្បីធ្វើកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយនឹងលោកជំទាវ ក៏ដូចជាស្ថានទូតតួកគី ដើម្បីរួមចំណែកពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការ ដើម្បីនាំមកនូវផលប្រយោជន៍ទៅវិញទៅមកជូនប្រជាជន និងប្រទេសទាំងពីរ។

តាមរយៈលោកជំទាវឯកអគ្គរដ្ឋទូត សម្ដេចប្រមុខរដ្ឋស្ដីទីបានពាំនាំនូវព្រះរាជបណ្ដាំសួរសុខទុក្ខ សេចក្ដីនឹករលឹកពីព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** និងថ្នាក់ដឹកនាំកំពូលជាតិ នៃព្រះរាជាណាចក្រកម្ពុជា ជូនចំពោះឯកឧត្ដមប្រធានាធិបតី ថ្នាក់ដឹកនាំកំពូលគ្រប់លំដាប់ថ្នាក់ នៃសាធារណរដ្ឋតួកគី។

សម្ដេចប្រមុខរដ្ឋស្ដីទីបានប្រសិទ្ធពរជូនលោកជំទាវឯកអគ្គរដ្ឋទូត សូមមានសុខភាពល្អ និងទទួលបានជោគជ័យក្នុងបេសកកម្មការទូតដ៏ឧត្ដុង្គឧត្ដម៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម្ដេចប្រមុខរដ្ឋស្ដីទី ថតរូបអនុស្សាវរីយ៍ជាមួយលោកជំទាវ UIKU Kocaefe*

# សម្តេចប្រមុខរដ្ឋស្តីទីអនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ ចូលជូនសារតាំង និងសម្តែងការគួរសម




*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ទទួលសារតាំងពីឯកឧត្តម Stenfan Anton Messerer*

នាព្រឹកថ្ងៃពុធ ទី៧ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ៩:០០នាទី សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម Stenfan Anton Messerer ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបជូនសារតាំង និងសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។

ក្នុងព្រះបរមនាមព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានសម្តែងអំណរសាទរស្វាគមន៍ចំពោះឯកឧត្តម Stenfan Anton Messerer ត្រូវបានឯកឧត្តមប្រធានាធិបតី នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងឱកាសនោះ ឯកឧត្តម Stenfan Anton Messerer បានសម្តែងនូវការពេញចិត្ត និងវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងប្រទេសទាំងពីរ។ ជាមួយគ្នានោះ ឯកឧត្តមក៏បានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើនយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជាផងដែរ។

ឯកឧត្តមឯកអគ្គរដ្ឋទូតបានបញ្ជាក់ថា តាមរយៈបេសកកម្មការទូតរបស់ឯកឧត្តមនៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមនឹងខិតខំរួមចំណែកពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងរដ្ឋាភិបាល




*ទិដ្ឋភាពក្នុងពិធីចូលជូនសារតាំង*



*ទិដ្ឋភាពក្នុងពិធីជួបសម្តែងការគួរសម*

ប្រជាជន និងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរថែមទៀត។

សម្តេចប្រមុខរដ្ឋស្តីទីបានកត់សម្គាល់ដោយសេចក្តីរីករាយចំពោះទំនាក់ទំនងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រជាជន និងប្រទេសទាំងពីរ ដែលមានការរីកចម្រើនជាបន្តបន្ទាប់។ សម្តេចមានជំនឿជឿជាក់ថា ក្នុងឋានៈឯកឧត្តមជាឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមនឹងបន្តខិតខំថែរក្សាប្រពៃណីដ៏ល្អ នៃចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរ ដែលមានទំនាក់ទំនងជាយូរលង់ណាស់មកហើយឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។

ក្នុងនាមប្រជាជនកម្ពុជា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចបានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលសហព័ន្ធអាល្លឺម៉ង់ ដែលបានផ្តល់ជំនួយអភិវឌ្ឍដល់កម្ពុជាលើវិស័យអប់រំ សុខាភិបាល ការបោសសម្អាតមីន សាលាក្តីខ្មែរក្រហម អភិបាលកិច្ច និងអភិវឌ្ឍន៍វិស័យថាមពលនៅជនបទ។

សម្តេចប្រមុខរដ្ឋស្តីទីបានបញ្ជាក់ថា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នជាតិ នៃព្រះរាជាណាចក្រកម្ពុជាត្រៀមខ្លួនជានិច្ច ដើម្បីធ្វើកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយនឹងឯកឧត្តម ក៏ដូចជាស្ថានទូតនៃសហព័ន្ធអាល្លឺម៉ង់ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការនាំមកនូវផលប្រយោជន៍ទៅវិញទៅមកជូនប្រជាជន និងប្រទេសទាំងពីរ។

តាមរយៈឯកឧត្តមឯកអគ្គរដ្ឋទូត សម្តេចប្រមុខរដ្ឋស្តីទីបានពាំនាំនូវព្រះរាជបណ្តាំសួរសុខទុក្ខ សេចក្តីនឹករលឹកពីព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** និងថ្នាក់ដឹកនាំកំពូលជាតិ នៃព្រះរាជាណាចក្រកម្ពុជា ជូនចំពោះឯកឧត្តមប្រធានាធិបតី និងថ្នាក់ដឹកនាំកំពូលគ្រប់លំដាប់ថ្នាក់ នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់។

សម្តេចប្រមុខរដ្ឋស្តីទីបានប្រសិទ្ធពរជូនឯកឧត្តមឯកអគ្គរដ្ឋទូត សូមមានសុខភាពល្អ និងទទួលបានជោគជ័យក្នុងបេសកកម្មការទូតដ៏ឧត្តុង្គឧត្តម៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម្តេចប្រមុខរដ្ឋស្តីទី ថតរូបអនុស្សាវរីយ៍ជាមួយឯកឧត្តម Stenfan Anton Messerer*

# សម្តេចប្រមុខរដ្ឋស្តីទីអនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតគ្វាតេម៉ាឡា ចូលជូនសារតាំង





*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ទទួលសារតាំងពីឯកឧត្តម Carlos Humberto Jiménez Licona*

នាព្រឹកថ្ងៃអង្គារ ទី១៣ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ៩:០០នាទី សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម Carlos Humberto Jiménez Licona ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋគ្វាតេម៉ាឡា ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជូនសារតាំង នៅវិមានព្រឹទ្ធសភា។

ក្នុងព្រះបរមនាមព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានសម្តែងអំណរសាទរស្វាគមន៍ចំពោះ ឯកឧត្តម Carlos Humberto Jiménez Licona ត្រូវបានឯកឧត្តមប្រធានាធិបតី នៃសាធារណរដ្ឋគ្វាតេម៉ាឡា តែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋគ្វាតេម៉ាឡា ប្រចាំព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងឱកាសនោះ ឯកឧត្តម Carlos Humberto Jiménez Licona បានសម្តែងនូវការពេញចិត្ត និងវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងប្រទេសទាំងពីរ។ ឯកឧត្តមមានជំនឿថា តាមរយៈបេសកកម្មការទូតរបស់ឯកឧត្តមនៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមនឹងខិតខំរួមចំណែកពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរលើវិស័យវប្បធម៌ និងវិស័យពាណិជ្ជកម្មឱ្យកាន់តែខ្លាំងក្លាថែមទៀត ដោយសារតែពាណិជ្ជកម្មរវាងប្រទេសទាំងពីរនៅមានកម្រិតទាបនៅឡើយ។ ចំពោះប្រទេសកម្ពុជា ជាប្រទេសដែលមានវប្បធម៌





*ទិដ្ឋភាពក្នុងពិធីចូលជូនសារតាំង*






*ទិដ្ឋភាពក្នុងពិធីចូលជួនសារតាំង*

សម្បូរបែប ជាពិសេសរមណីយដ្ឋានអង្គរ និងតំបន់ទេសចរណ៍ជាច្រើន។

ឯកឧត្ដមឯកអគ្គរដ្ឋទូតបានបញ្ជាក់ថា ឯកឧត្ដមនឹងខិតខំជំរុញទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងសាធារណរដ្ឋគ្វាតេម៉ាឡាជាមួយនឹងតំបន់អាស៊ានឱ្យកាន់តែប្រសើរឡើងថែមទៀត ពីព្រោះប្រទេសជាសមាជិកអាស៊ានមានសក្ដានុពលក្នុងការផ្លាស់ប្ដូរសេដ្ឋកិច្ច និងពាណិជ្ជកម្ម។

ក្នុងឱកាសនោះដែរ ឯកឧត្ដមឯកអគ្គរដ្ឋទូតបានពាំនាំនូវការផ្ដាំផ្ញើសួរសុខទុក្ខប្រកបដោយក្ដីនឹករលឹកពីឯកឧត្ដមប្រធានាធិបតី នៃសាធារណរដ្ឋគ្វាតេម៉ាឡា ថ្វាយព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្ដម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងជូនចំពោះថ្នាក់ដឹកនាំកំពូលជាតិ នៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

សម្ដេចប្រមុខរដ្ឋស្ដីទីបានកត់សម្គាល់ដោយសេចក្ដីរីករាយចំពោះទំនាក់ទំនងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រជាជន និងប្រទេសទាំងពីរ ដែលមានការរីកចម្រើនជាបន្តបន្ទាប់។ សម្ដេចមានជំនឿជឿជាក់ថា ក្នុងឋានៈឯកឧត្ដមជាឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋគ្វាតេម៉ាឡា ប្រចាំព្រះរាជាណាចក្រកម្ពុជា ឯកឧត្ដមនឹងបន្តខិតខំថែរក្សាប្រពៃណីដ៏ល្អ នៃចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរ ដែលមានទំនាក់ទំនងជាយូរលង់ណាស់មកហើយឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។

សម្ដេចប្រមុខរដ្ឋស្ដីទីបានបញ្ជាក់ថា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នជាតិ នៃព្រះរាជាណាចក្រកម្ពុជាត្រៀមខ្លួនជានិច្ច ដើម្បីធ្វើកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយនឹងឯកឧត្ដមឯកអគ្គរដ្ឋទូត ដើម្បីលើកកម្ពស់ទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការនឹងនាំមកនូវផលប្រយោជន៍ដ៏ធំធេងទៅវិញទៅមកសម្រាប់ប្រជាជន និងប្រទេសទាំងពីរ។

តាមរយៈឯកឧត្ដមឯកអគ្គរដ្ឋទូត សម្ដេចប្រមុខរដ្ឋស្ដីទីបានពាំនាំនូវព្រះរាជបណ្ដាំសួរសុខទុក្ខ សេចក្ដីនឹករលឹកពីព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្ដម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចព្រះមហាក្សត្រី **នរោត្ដម មុនិនាថ សីហនុ** និងថ្នាក់ដឹកនាំកំពូលជាតិ នៃព្រះរាជាណាចក្រកម្ពុជា ជូនចំពោះឯកឧត្ដមប្រធានាធិបតី និងថ្នាក់ដឹកនាំកំពូលគ្រប់លំដាប់ថ្នាក់ នៃសាធារណរដ្ឋគ្វាតេម៉ាឡា។

សម្ដេចប្រមុខរដ្ឋស្ដីទីបានប្រសិទ្ធពរជូនឯកឧត្ដមឯកអគ្គរដ្ឋទូត សូមមានសុខភាពល្អ និងទទួលបានជោគជ័យក្នុងបេសកកម្មការទូតដ៏ឧត្ដុង្គឧត្ដម៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គឹម សិទ្ធី)

# សម្ដេចប្រមុខរដ្ឋស្ដីទីអនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតបេឡារុស ចូលជូនសារតាំង




*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ទទួលសារតាំងពីឯកឧត្ដម Uladzimir BARAVIKOU ចូលជួបជូនសារតាំង និងសម្ដែងការគួរសម*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១៥ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង៩:០០នាទី សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្ដម Uladzimir BARAVIKOU ឯកអគ្គរដ្ឋទូត តែងតាំងថ្មី នៃសាធារណរដ្ឋបេឡារុស ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបជូនសារតាំង នៅវិមានព្រឹទ្ធសភា។

ក្នុងព្រះបរមនាមព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមសម្ដេចផ្ទាល់ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** បានសម្ដែងអំណរសាទរស្វាគមន៍ចំពោះឯកឧត្ដម Uladzimir BARAVIKOU ត្រូវបានឯកឧត្ដមប្រធានាធិបតី នៃសាធារណរដ្ឋបេឡារុស តែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋបេឡារុស ប្រចាំព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងឱកាសនោះ ឯកឧត្ដម Uladzimir BARAVIKOU បានសម្ដែងនូវការពេញចិត្ត និងវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរ។ ជាមួយគ្នានោះ ឯកឧត្ដមក៏បានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើនយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជាផងដែរ។

ឯកឧត្ដមឯកអគ្គរដ្ឋទូតបានសម្ដែងនូវការអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះប្រទេសកម្ពុជា ដែលទទួលបានជោគជ័យក្នុងពេលធ្វើជាប្រធានអាស៊ានប្ដូរវេន ដែលធានា




*ទិដ្ឋភាពក្នុងពិធីចូលជូនសារតាំង*



*ទិដ្ឋភាពក្នុងពិធីចូលជូនសារតាំង*

បាននូវស្ថិរភាពនយោបាយក្នុងតំបន់ និងពិភពលោក។ ឯកឧត្តមមានជំនឿថា តាមរយៈបេសកកម្មការទូតរបស់ឯកឧត្តមនៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមនឹងខិតខំរួមចំណែកពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរក្នុងនោះទំនាក់ទំនងរវាងស្ថាប័ននីតិប្បញ្ញត្តិ នៃប្រទេសទាំងពីរឱ្យកាន់តែប្រសើរឡើងថែមទៀត។

សម្ដេចប្រមុខរដ្ឋស្ដីទីបានសម្ដែងនូវការពេញចិត្តចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរ។ សម្ដេចមានជំនឿជឿជាក់ថា ក្នុងឋានៈឯកឧត្តមជាឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋបេឡារុសប្រចាំព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមនឹងបន្តខិតខំពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងប្រទេសទាំងពីរ និងប្រជាជនទាំងពីរឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។

សម្ដេចប្រមុខរដ្ឋស្ដីទីបានបញ្ជាក់ថា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នជាតិ នៃព្រះរាជាណាចក្រកម្ពុជាត្រៀមខ្លួនជានិច្ចដើម្បីធ្វើកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយនឹងឯកឧត្តមឯកអគ្គរដ្ឋទូត ដើម្បីលើកកម្ពស់ទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការនឹងនាំមកនូវផលប្រយោជន៍ដ៏ធំធេងទៅវិញទៅមកសម្រាប់ប្រជាជននិងប្រទេសទាំងពីរ។

តាមរយៈឯកឧត្តមឯកអគ្គរដ្ឋទូត សម្ដេចប្រមុខរដ្ឋស្ដីទីបានពាំនាំនូវព្រះរាជបណ្ដាំសួរសុខទុក្ខ និងសេចក្ដីនឹករលឹកពីព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** និងថ្នាក់ដឹកនាំកំពូលជាតិ នៃព្រះរាជាណាចក្រកម្ពុជា ជូនចំពោះឯកឧត្តមប្រធានាធិបតី និងថ្នាក់ដឹកនាំកំពូលគ្រប់លំដាប់ថ្នាក់ នៃសាធារណរដ្ឋបេឡារុស។

សម្ដេចប្រមុខរដ្ឋស្ដីទីបានប្រសិទ្ធពរជូន ឯកឧត្តមឯកអគ្គរដ្ឋទូត សូមមានសុខភាពល្អ និងទទួលបានជោគជ័យក្នុងបេសកកម្មការទូតដ៏ឧត្តុង្គឧត្តម៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម្ដេចប្រមុខរដ្ឋស្ដីទី ថតរូបអនុស្សាវរីយ៍ជាមួយឯកឧត្តម Uladzimir BARAVIKOU*

# ព្រឹទ្ធសភាកាន់បិណ្ឌវេនទី១៤ នៅវត្តបទុមវត្តីរាជវរារាម



*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ីម កា និងឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន*

ក្នុងឱកាសបិណ្ឌទី១៤ នារសៀលថ្ងៃសុក្រ ទី២៣ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ីម កា** ប្រធានស្ដីទីព្រឹទ្ធសភា ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញសូត្រមន្តកាន់បិណ្ឌវេនទី១៤ នៅវត្តបទុមវត្តីរាជវរារាម ស្ថិតក្នុងសង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

នាឱកាសនោះ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតប្រធានស្ដីទីព្រឹទ្ធសភា ឯកឧត្តមកិត្តិសង្គហបណ្ឌិតអនុប្រធានទី២ព្រឹទ្ធសភា និងសមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញថ្វាយនូវគ្រឿងសក្ការៈបូជា ទៀន ធូប ផ្កាភ្ញី និងប្រារព្ធកិច្ចនមស្ការចំពោះព្រះរត្នត្រ័យ សមាទានសីល និមន្តព្រះសង្ឃសូត្រធម៌ស្វាធ្យាយ ចម្រើនព្រះបរិត្ត និងពុទ្ធជ័យមង្គល ព្រមទាំងស្ដាប់ព្រះធម្មវិសេសទេសនា ដើម្បីប្រមូលកុសលផលបុណ្យឧទ្ទិសកុសលជូនដួងវិញ្ញាណក្ខន្ធលោកអ្នកមានគុណ បុព្វបុរសជាតិ យុទ្ធជន យុទ្ធនារី ដែលបានពលី និងទទួលមរណភាពទៅកាន់លោកខាងមុខ។

ចំពោះនៅព្រឹកថ្ងៃសៅរ៍ ទី២៤ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ីម កា** ប្រធានស្ដីទីព្រឹទ្ធសភា ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបន្តអញ្ជើញនាំយកចង្ហាន់ ទេយ្យទាន និងគ្រឿងបរិក្ខារ រាប់បាត្រវេរប្រគេនព្រះសង្ឃ ពហូទេវាដារឆ្លងឧទ្ទិសកុសលជូនដួងវិញ្ញាណក្ខន្ធញាតិកា ឥស្សរជន និងយុទ្ធជន ដែលបានពលីជីវិត ដើម្បីជាតិមាតុភូមិ ជាពិសេសដល់ដួងវិញ្ញាណក្ខន្ធរបស់សម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** និងលោកជំទាវ **ញ៉ែម សឿន ជា ស៊ីម** សម្ដេច **ស៊ីសុវត្ថិ ជីវ័ន មុនីរ៉ាក្ស** ឯកឧត្តម **នៃ ប៉េណា** និងសមាជិកសមាជិកាព្រឹទ្ធសភាដែលបានទទួលមរណកាលទៅកាន់លោកខាងមុខ ជាកិច្ចបញ្ចប់នៃពិធីបុណ្យកាន់បិណ្ឌវេនទី១៤។





*ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញសូត្រមន្តកាន់បិណ្ឌវេនទី១៤*



ទិដ្ឋភាពក្នុងពិធីបិណ្យកាន់បិណ្ឌវេនទី១៤ នៅវត្តបទុមវត្តីរាជវរារាម

ទេយ្យទាន និងទេយ្យវត្ថុដែលវេរប្រគេនព្រះសង្ឃនាឱកាសនោះរួមមាន៖ បាយបត្តបូរ៨ឈុត សាដក៣៥ឈុត រៀបចំចង្ហាន់ប្រគេនព្រះសង្ឃ៤៧៤អង្គ ផ្លែឈើ៣៣កន្ត្រក នំខ្មែរ៣៣កន្ត្រក និងទេយ្យទានផ្សេងៗ១ឈុតធំ ប្រគេនបច្ច័យព្រះសង្ឃចំនួន៤៧៤អង្គ ព្រមទាំងប្រគេនបច្ច័យវេនបិណ្ឌមួយចំនួនធំ និងជូនថវិកាដល់លោកតាជី លោកយាយជីចំនួន៥៦នាក់ ដោយក្នុងម្នាក់ៗទទួលបានក្រណាត់ស១ដុំ និងថវិកាមួយចំនួន។

សូមជម្រាបថា ពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ គឺជាពិធីបុណ្យជាតិ ដែលប្រជាពលរដ្ឋខ្មែរដែលជាអ្នកកាន់ព្រះពុទ្ធ-សាសនា តែងតែប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ ចាប់ពីថ្ងៃ១រោច ដល់ថ្ងៃ១៥រោច ខែភទ្របទ ដោយចែកចេញជាពីរដំណាក់ ក្នុងនោះ គឺចាប់ពីថ្ងៃ១រោច រហូតដល់ថ្ងៃ១៤រោច ខែភទ្របទ ដែលជាថ្ងៃកាន់បិណ្ឌ និងថ្ងៃ១៥រោច គឺជាថ្ងៃបុណ្យភ្ជុំបិណ្ឌ។ ពិធីបុណ្យភ្ជុំបិណ្ឌនេះមានគោលបំណងដើម្បីឧទ្ទិសមហាកុសលផលបុណ្យថ្វាយ ប្រគេន និងជូនដល់បុព្វការីជន មានអតីតព្រះមហាក្សត្រ មហាក្សត្រីយានី ព្រះគ្រូឧបជ្ឈាយាចារ្យ ជីដូន ជីតា មាតាបិតា ដែលទ្រង់បានសោយព្រះទិវង្គត អនិច្ចធម្ម និងធ្វើមរណកាលទៅហើយផងដល់តស្សូរជន និងយុទ្ធជន ដែលបានពលីជីវិតដើម្បីជាតិមាតុភូមិជាដើមផងដែរ ព្រមទាំងឱ្យកូនខ្មែរយើងបានបំពេញនូវអំពើល្អ៕

(អត្ថបទ៖ អ៊ុក ប៉ូលីន រូបភាព៖ គង់ យ៉ារីន)







ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញរាប់បាត្រ

# ព្រឹទ្ធសភារៀបចំពិធីសម្ពោធស្លាកសមិទ្ធផលជំនួយរបស់ស្ថានទូតចិនប្រចាំកម្ពុជា



ឯកឧត្តម វ៉ាង វិនធាន និងឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ជាគណៈអធិបតីភាព

ស្លាកសមិទ្ធផលលើការជួសជុលអគារក្រហម និងបណ្ណាល័យព្រឹទ្ធសភា ដែលជាជំនួយរបស់ស្ថានទូត នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា ត្រូវបានរៀបចំពិធីសម្ពោធនារសៀលថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា និងឯកឧត្តម **វ៉ាង វិនធាន** ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។

ក្នុងឱកាសនោះ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា បានជម្រាបជូនអង្គពិធីជ្រាបថា ក្នុងបរិបទនៃជំងឺកូវីដ-១៩ ស្ថានទូត នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំកម្ពុជា បានឧបត្ថម្ភគាំទ្រលើគម្រោងជួសជុលកែលម្អ និងបំពាក់កម្មវិធីគ្រប់គ្រងបណ្ណាល័យអេឡិចត្រូនិកដល់បណ្ណាល័យព្រឹទ្ធសភាកម្ពុជា ក្នុងទឹកប្រាក់ចំនួន៧ម៉ឺនដុល្លារអាមេរិក និងគម្រោងជួសជុលអគារក្រហម ក្នុងទឹកប្រាក់ចំនួន៤២.៥០០ដុល្លារអាមេរិក ដើម្បីកែលម្អបរិស្ថានការងារក្នុងព្រឹទ្ធសភាឱ្យកាន់តែល្អប្រសើរថែមទៀត។



ឯកឧត្តម ឡោក ឆាយ ឡើងរាយការណ៍ជូនអង្គពិធី

មានប្រសាសន៍នៅក្នុងឱកាសនោះ ឯកឧត្តម **វ៉ាង វិនធាន** បានបញ្ជាក់ថា ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា តែងរក្សាទំនាក់ទំនងចំណងមិត្តភាពជាមួយនឹងសាធារណរដ្ឋប្រជាមានិតចិនក្នុងការរួមចំណែកយ៉ាងសំខាន់លើកិច្ចសហប្រតិបត្តិការទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងស្ថាប័ននីតិប្បញ្ញត្តិ នៃប្រទេសទាំងពីរ និងការជំរុញអភិវឌ្ឍទំនាក់ទំនងរវាងប្រទេសទាំងពីរ។ ចាប់តាំងពីឆ្នាំ២០២១មក ស្ថានទូត នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា បានផ្តល់ជំនួយលើគម្រោងជួសជុលអគារក្រហម និងបណ្ណាល័យព្រឹទ្ធសភា គឺជាភារកិច្ចដែលក្នុងនាមជាមិត្តដែកថែប។ ឯកឧត្តមមានជំនឿជឿជាក់ថា បន្ទាប់ពីបញ្ចប់គម្រោងទាំងពីរនេះរួច បរិយាកាសការងារក្នុងព្រឹទ្ធសភានឹងមានភាពប្រសើរឡើងថែមមួយកម្រិតទៀត។

ឯកឧត្តម **វ៉ាង វិនធាន** បានវាយតម្លៃខ្ពស់ចំពោះ





*ឯកឧត្តម វ៉ាង វិនធាន និងឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ឡើងមានប្រសាសន៍ក្នុងអង្គពិធី*

ទំនាក់ទំនងរវាងសាធារណរដ្ឋប្រជាមានិតចិន និងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានបង្កើត និងបីបាច់ថែទាំយ៉ាងយកចិត្តទុកដាក់ដោយថ្នាក់ដឹកនាំចិនជំនាន់មុន និងព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"។

ឯកឧត្តម **វ៉ាង វិនធាន** បានបញ្ជាក់ថា ប្រទេសចិន និងប្រទេសកម្ពុជា គឺជាមិត្តដែកថែបយ៉ាងពិតប្រាកដ។ ភាគីចិនសូមថ្លែងអំណរគុណចំពោះការប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់របស់កម្ពុជាអំពីគោលការណ៍ចិនតែមួយ។ ភាគីចិនក៏គាំទ្រយ៉ាងម៉ឺងម៉ាត់ដល់ភាគីកម្ពុជាក្នុងការការពារអធិបតេយ្យភាពជាតិ ឯករាជ្យភាព និងសេចក្ដីថ្លៃថ្នូររបស់ជាតិ គាំទ្រយ៉ាងមុតមាំដល់ភាគីកម្ពុជាក្នុងការដើរលើមាគ៌ាអភិវឌ្ឍន៍ដែលសមស្របនឹងលក្ខខណ្ឌជាតិរបស់ខ្លួន គាំទ្រយ៉ាងម៉ឺងម៉ាត់ដល់ភាគីកម្ពុជាក្នុងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍សេដ្ឋកិច្ច និងការកែលម្អជីវភាពរស់នៅរបស់ប្រជាជន។

ក្រោយពីបានស្ដាប់របាយការណ៍របស់ឯកឧត្តមអគ្គលេខាធិការស្ដីទីព្រឹទ្ធសភា និងប្រសាសន៍របស់ឯកឧត្តម **វ៉ាង វិនធាន** រួចមក ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានវាយតម្លៃខ្ពស់ដោយសេចក្ដីពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងស្ថានទូត នៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជាដែលតែងតែមានទំនាក់ទំនងជាប្រចាំ និងកាន់តែប្រសើរឡើង ទោះបីជាស្ថិតក្នុងការលំបាកដោយសារការរីករាលដាលជំងឺកូវីដ-១៩ក៏ដោយ។ នេះបង្ហាញឱ្យឃើញពីទំនាក់ទំនងមិត្តភាពកម្ពុជា-ចិនកាន់តែរឹងមាំ និងមានភាពធន់នឹងវិបត្តិ មិនថាសម្រាប់ពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគត ដែលទំនាក់ទំនងមិត្តភាពដែកថែបនេះនឹងក្លាយទៅជាផលប្រយោជន៍ដ៏ធំធេងសម្រាប់ប្រជាជន និង





*សមាជិក សមាជិកាព្រឹទ្ធសភា គណៈប្រតិភូចិន និងភ្ញៀវកិត្តិយស អញ្ជើញចូលរួមក្នុងអង្គពិធី*



*ទិដ្ឋភាពក្នុងអង្គពិធី*

កូនចៅកម្ពុជា-ចិន គ្រប់ជំនាន់ទៅមុខទៀត។

ឯកឧត្តមកិត្តិសង្គហបណ្ឌិតបានរំលឹកថា ជំនួយរបស់ប្រទេសចិនជូនដល់ព្រឹទ្ធសភាកម្ពុជានាពេលនេះ មិនមែនជាជំនួយលើកទី១ ហើយរឹតតែមិនមែនជាជំនួយលើកចុងក្រោយនោះទេ ដោយសារតែប្រទេសចិនតែងយកចិត្តទុកដាក់ជួសជុល និងកែលម្អឱ្យកាន់តែប្រសើរនូវហេដ្ឋារចនាសម្ព័ន្ធដែលជាជំនួយរបស់ប្រទេសចិន។ ជាក់ស្តែង អគារបណ្ណាល័យព្រឹទ្ធសភាត្រូវបានសាងសង់ក្រោមជំនួយកិច្ចសហប្រតិបត្តិការរបស់សាធារណរដ្ឋប្រជាមានិតចិន ហើយនាពេលនេះត្រូវបានជួសជុល ធ្វើទំនើបកម្មឱ្យក្លាយជាបណ្ណាល័យអេឡិចត្រូនិក ដែលនេះគឺជាកាយវិការដ៏សប្បុរសល្អប្រពៃ និងយកចិត្តទុកដាក់ខ្ពស់របស់មិត្តចិនមកលើប្រទេសកម្ពុជា។

ឯកឧត្តមកិត្តិសង្គហបណ្ឌិតបានស្នើសុំឯកឧត្តមឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា ជួយជំរុញដល់គម្រោងកសាងអគារសាលប្រជុំរបស់ព្រឹទ្ធសភា ដែលមានការឯកភាពពីថ្នាក់ដឹកនាំរួចមកហើយនោះឱ្យបានចេញជារូបរាងឆាប់ៗ ដើម្បីប្រើប្រាស់ជាឧត្តមប្រយោជន៍ដល់ព្រឹទ្ធសភាអាណត្តិទី៥ នាឆ្នាំ២០២៤ខាងមុខ និងសូមពិនិត្យលទ្ធភាពបន្តជួយផ្តល់ជំនួយសម្ភារបរិក្ខារបច្ចេកទេសគ្រឿងអេឡិចត្រូនិក មធ្យោបាយដឹកជញ្ជូន និងបន្តផ្តល់អាហារូបករណ៍រយៈពេលវែង-ខ្លី ដល់មន្ត្រីផ្នែកស្រាវជ្រាវការទូតសភា ទំនាក់ទំនងអន្តរជាតិ ផ្នែកភាសាចិន និងទៅសិក្សាឈ្វេងយល់ពីសភានយោបាយប្រជាជនចិន និងបទពិសោធន៍តាមវិស័យនានា ដើម្បីយកមកបម្រើសេវាឱ្យកាន់តែប្រសើរឡើងថែមទៀតដល់សមាជិក និងថ្នាក់ដឹកនាំព្រឹទ្ធសភាកម្ពុជា៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ គឹម សិទ្ធី)



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ថតរូបអនុស្សាវរីយជាមួយឯកឧត្តម វ៉ាង វិនធាន*

## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ



❋នាព្រឹកថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារបានអញ្ជើញប្រារព្ធពិធីបង្សុកូល ឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធមហាឧបាសក **គង់ ខាត់** និងញាតកាទាំង៧សន្ដាន នៅវត្តសុវណ្ណគីរី (ហៅវត្តជើងផ្នុក) ស្ថិតក្នុងភូមិជើងផ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម។



❋នាព្រឹកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ បានអញ្ជើញប្រារព្ធពិធីបង្សុកូល ឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធមាតា បិតា ញាតកាទាំង៧សន្ដាន នៅឃុំកោះសូទិន ខេត្តកំពង់ចាម។



❋នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ បានអញ្ជើញប្រារព្ធពិធីបង្សុកូល ដើម្បីឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធបុព្វការីជន ដែលបានពលីជីវិតក្នុងការតស៊ូរំដោះជាតិ មាតុភូមិកម្ពុជា នៅវត្តបទុមវតីរាជវរារាម (ឬវត្តបទុមវតី) រាជធានីភ្នំពេញ។



❋នាព្រឹកថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា ព្រមទាំងកូន និងចៅ បានអញ្ជើញចូលរួមពិធីកាន់បិណ្ឌវេនទី១១ ដើម្បីឧទ្ទិសកុសលផលបុណ្យជូនដល់ ជីដូន ជីតា ញាតកាទាំង៧សន្ដាន ចំនួន៤វត្ត ស្ថិតក្នុងឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ៕

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា

❈ឯកឧត្ដម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញ៖

-ប្រជុំជាមួយមន្ត្រីលេខាធិការដ្ឋានអមគណៈកម្មការទី១ព្រឹទ្ធសភា និងមន្ត្រីការិយាល័យអមភូមិភាគទី៨ អំពីការត្រៀមជួបសវនាការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងក្រសួងកិច្ចការនារី និងករណីសំណើសុំរបស់តំណាងជនជាតិដើមភាគតិច១៦នាក់ មកពី១៦អម្បូរជនជាតិ ដើម្បីបង្ហាញ និងសុំពិគ្រោះយោបល់ផ្ដល់ធាតុចូលក្នុងសេចក្ដីព្រាងច្បាប់ស្ដីពី តំបន់ការពារធម្មជាតិឆ្នាំ២០០៨ និងច្បាប់ស្ដីពីព្រៃឈើឆ្នាំ២០០២ និងការរៀបចំរបាយការណ៍ និងលទ្ធផលការងារប្រចាំឆ្នាំ ២០២២ និងប្រចាំអាណត្តិរបស់គណៈកម្មការ ព្រមទាំងសួរសុខទុក្ខអំពីស្ថានភាពសុខភាពរបស់មន្ត្រី និងក្រុម-គ្រួសារ នៅសាលគណៈកម្មការទី១ព្រឹទ្ធសភា នាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២។



-ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១ព្រឹទ្ធសភា ដើម្បីស្ដាប់សេចក្ដីរាយការណ៍របស់មន្ត្រីនាយកដ្ឋានស្រាវជ្រាវទូទៅ និងនាយកដ្ឋានស្រាវជ្រាវច្បាប់អំពីការត្រៀមជួបសវនាការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងក្រសួងកិច្ចការនារី និងករណីសំណើសុំរបស់តំណាងជនជាតិដើមភាគតិច១៦នាក់ មកពី១៦អម្បូរជនជាតិ ដើម្បីបង្ហាញ និងសុំពិគ្រោះយោបល់ផ្ដល់ធាតុចូលក្នុងសេចក្ដីព្រាងច្បាប់ស្ដីពី តំបន់ការពារធម្មជាតិឆ្នាំ២០០៨ និងច្បាប់ស្ដីពីព្រៃឈើ ឆ្នាំ២០០២ នៅសាលប្រជុំគណៈ-កម្មការទី១ព្រឹទ្ធសភា នាថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០២២។



❈នាថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្ដម **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញជាអធិបតី-ភាពក្នុងពិធីធ្វើបទបង្ហាញស្ដីពី "បទពិសោធន៍ និងតួនាទីរបស់ព្រឹទ្ធសភា និងទស្សនវិស័យទាក់ទងនឹងឱកាសសម្រាប់ការចូលរួមរបស់សាធារណជន និងគណនេយ្យភាពក្នុងអំឡុងវដ្ដថវិកា" ដែលសិក្សាស្រាវជ្រាវដោយនាយកដ្ឋានស្រាវជ្រាវថវិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ នៅសាល-ប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា។

❈លោកជំទាវ **ឌី ប្ញ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញដឹកនាំ៖



-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា នៅសាល-ប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា នាថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០២២ ដើម្បីបូកសរុបលទ្ធផលសកម្មភាពការងាររបស់គណៈកម្មការទី៥ ប្រចាំខែសីហា ឆ្នាំ២០២២ បូកសរុបថវិកាចំណូល-ចំណាយរបស់គណៈកម្មការទី៥ ប្រចាំខែសីហា ឆ្នាំ២០២២ រាយការណ៍អំពីសភាពការណ៍ថ្មីៗនៅលើពិភពលោក និងបញ្ហាផ្សេងៗ។

-ប្រជុំនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២ នៅសាលប្រជុំពិសេស វិមានព្រឹទ្ធសភា ដើម្បីត្រៀមរៀបចំសិក្ខាសាលា



សភាប្រើភាសាបារាំង APF ស្ដីពី ស្វ័យភាពសេដ្ឋកិច្ចរបស់ស្ត្រីនៅតំបន់ជនបទ និងការចរាចរ និងសន្ទានុកម្មនៅក្នុងមជ្ឈដ្ឋានសភា ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២។

❋ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញបើកកិច្ចប្រជុំ៖



-ផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបាយការណ៍ស្ដីពី សកម្មភាពនិងលទ្ធផលការងារ របាយការណ៍ថវិការបស់គណៈកម្មការប្រចាំខែកញ្ញា ឆ្នាំ២០២២ នៅសាលប្រជុំពិសេស វិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២។



-ត្រៀមជួបពិភាក្សាការងារជាមួយនឹងគណៈប្រតិភូគណៈ-កម្មការសិក្សាស៊ើបអង្កេតអំពើពុករលួយ ការប្រព្រឹត្តខុស និងការពង្រឹងអភិបាលកិច្ចល្អរបស់ព្រឹទ្ធសភា នៃព្រះរាជា-ណាចក្រថៃឡង់ដ៍ នៅសាលប្រជុំពិសេស វិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២។



❋នាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ឡៅ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអនុញ្ញាតឱ្យមន្ត្រីនាយកដ្ឋានស្រាវជ្រាវទូទៅ ដើម្បីសុំយោបល់លើឯកសារស្រាវជ្រាវលើប្រធានបទ “វឌ្ឍនភាពការងារប្រយុទ្ធ-ប្រឆាំងអំពើជួញដូរមនុស្ស ពេស្យាចា និងទេសន្តប្រវេសន៍” នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។



❋នាព្រឹកថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធាន និងលោកជំទាវ **ម៉ុំ សណ្ដាប់** លេខា-ធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានប្រជុំជាមួយនឹងលោកស្រី **ខា ម៉ាលីកា** អនុប្រធាននាយកដ្ឋានទំនាក់-ទំនងអន្តរជាតិ និងលោក **ខួន សុគន្ធារិទ្ធ** ប្រធានលេខា-ធិការដ្ឋានអមគណៈកម្មការទី៨ព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាលើការរៀបចំឯកសារសម្រាប់ត្រៀមចូលរួមកិច្ច-ប្រជុំប្រចាំឆ្នាំ នៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិកលើកទី៣០ (APPF-30) ក្រោមមូលបទ “សភា និងការអភិវឌ្ឍប្រកបដោយចីរភាពក្រោយជំងឺកូវីដ-១៩” ដែលគ្រោងនឹងប្រព្រឹត្ត-ទៅចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២ នៅទីក្រុងបាងកក នៃព្រះរាជាណាចក្រថៃឡង់ដ៍ នាសាល-ប្រជុំគណៈកម្មការទី៨ ព្រឹទ្ធសភា៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្ដាភូមិភាគទាំង៨



❋នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **ម៉ី ឡាំ** អ្នកតំណាងរាស្ត្រមណ្ឌលខេត្តរតនគីរី និងជាសមាជិកគណៈកម្មការទី៤ នៃរដ្ឋសភា នៅភូមិអូរកន្សែង សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគីរី ។

❋ឯកឧត្តម **ជា ជេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបពិភាក្សាជាមួយនឹងក្រុមប្រឹក្សាសង្កាត់ក្រាំងធ្នង់ និងស្នៀន ដើម្បីពិភាក្សាការងារអំពី៖ ១-ការអនុវត្តផែនការឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ របស់សាលារាជធានីភ្នំពេញ និង២-ការណែនាំ និងការចងក្រងប្រជាពលរដ្ឋតាមបណ្ដាភូមិឱ្យចូលរួមពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ព្រមទាំងទៅធ្វើអត្តសញ្ញាណប័ណ្ណឱ្យបានគ្រប់ៗគ្នា នៅច្រកចេញចូលតែមួយសង្កាត់ក្រាំងធ្នង់ ដែលទើបតែបង្កើតមុនគេឆ្នាំ២០២២នេះ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន និងជូនសម្ភារប្រើប្រាស់មួយចំនួនដល់អ្នកចូលរួម នៅសាលាសង្កាត់ក្រាំងធ្នង់ នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២។

-ជាអធិបតីភាពក្នុងកិច្ចប្រជុំជាមួយនឹងក្រុមការងារបោះឆ្នោតគ្រប់ខណ្ឌទាំងអស់ក្នុងរាជធានីភ្នំពេញ ដើម្បីត្រៀមរៀបចំការងារក្នុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០២២ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ នាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២។





-ចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី៣ នៅវត្តជ័យឧត្តម ឃុំស្រះជីក ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ (មូលដ្ឋានដែលឯកឧត្តមធ្លាប់រស់នៅក្នុងសម័យប៉ុលពត) ដើម្បីអរគុណសន្តិភាព និងដើម្បីរំលឹកនឹកគុណដល់មាតា បិតា និងបងប្អូនញាតិសន្តានទាំងអស់ ដែលបានចែកឋានទៅ ព្រមទាំងនាំនូវគ្រឿងឧបភោគ បរិភោគ និងចង្ហាន់ប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សា ព្រមទាំងបច្ច័យសម្រាប់កសាងវត្តមួយចំនួន និងបានចែកទានដល់ឧបាសក ឧបាសិកា ចំណុះជើងវត្ត និងកុមារា កុមារី នាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២។



-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងឧបត្ថម្ភអង្ករចំនួន២៥គីឡូក្រាម និងថវិកាមួយចំនួន ជូនបងប្អូនប្រជាពលរដ្ឋរត់ម៉ូតូកង់បីចំនួន៥នាក់ នៅគេហដ្ឋានរបស់

ឯកឧត្តម ស្ថិតក្នុងភូមិសន្សំកុសលទី១ សង្កាត់បឹងទំពុនទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ នាថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២។

❃ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ ព្រឹទ្ធសភាបានអញ្ជើញ៖



-ចុះសួរសុខទុក្ខ និងនាំយកគ្រឿងឧបភោគ បរិភោគមួយចំនួន ជូនកងកម្លាំងបញ្ជាការដ្ឋានអង្គរក្ស ដែលកំពុងចូលរួមយ៉ាងសកម្មក្នុងការដាំកូនឈើនៅតំបន់ភ្នំតាម៉ៅ តាមបទបញ្ជាដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖ អង្ករ៥តោន ជ្រូក១៦ក្បាល មាន់៧៥០ក្បាល ស៊ុតមាន់៧២០០គ្រាប់ សាច់ប៉ាតេ១០០គីឡូក្រាម សាច់ក្រក២៥៥គីឡូក្រាម ទឹកក្រូច១០០កេស ទឹកបរិសុទ្ធ១០០កេស ប្រេងម៉ាស៊ូត៣.០០០លីត្រ ព្រមទាំងឧបត្ថម្ភកូនឈើប្រណិតចំនួន៤៧.៧៧០ដើម នៅភ្នំតាម៉ៅ ស្រុកសំរោង ខេត្តតាកែវ នាព្រឹកថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលក្រុមការងារសាងសង់រោងចក្រផលិតចំណីសត្វទី២ នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២។

-ជួបសំណេះសំណាល សួរសុខទុក្ខកម្មករកំពុងប្រមូលផលកៅស៊ូ ព្រមទាំងចុះពិនិត្យមើលម៉ាស៊ីនអគ្គិសនីដើរដោយថាមពលហ្គាស់លាមកជ្រូក នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២២។

-ជួបសំណេះសំណាល សួរសុខទុក្ខកម្មករ ព្រមទាំងចុះដឹកនាំក្រុមការងារបច្ចេកទេសសំណង់ កសិកម្ម និងផ្នែកថែទាំសត្វព្រៃ ដើម្បីពិនិត្យកែលម្អឡើងវិញទីកន្លែងចិញ្ចឹមសត្វព្រៃឱ្យមានផាសុកភាព នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលប្រព័ន្ធប្រឡាយបង្ហូរទឹកល្ង និងហេដ្ឋារចនាសម្ព័ន្ធនានា នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងណែនាំដល់កម្មករអំពីរបៀបថែទាំដំណាំផ្សេងៗ និងចុះពិនិត្យមើលទំនប់ទឹក ហេដ្ឋារចនាសម្ព័ន្ធនានា នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលទំនប់ទឹក ចម្ការឈើក្រញូង និងហេដ្ឋារចនាសម្ព័ន្ធនានា នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២។

❃នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលពិភាក្សាការងារជាមួយនឹងសមាជិកសមាជិកាក្រុមប្រឹក្សាឃុំ នៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង។

❃លោកជំទាវ **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល សួរសុខទុក្ខក្រុមប្រឹក្សាឃុំជ្រៃលាស់ និងពិភាក្សាការងារអំពីបញ្ហាផ្សេងៗ ព្រមទាំងជួបសំណេះសំណាល សួរសុខទុក្ខ លោក លោកស្រីជាថ្នាក់ដឹកនាំរដ្ឋបាលស្រុកពញាឮ និងឧបត្ថម្ភថវិកាមួយចំនួន និងវីតាមីនសេចំនួន២២ប្រអប់ធំ ថ្នាំលាបរបួសបេតាឌីនចំនួន១៣ប្រអប់ធំ ស្ថិតក្នុងស្រុកពញាឮ ខេត្តកណ្ដាល នាព្រឹកថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២២។

-ជួបសំណេះសំណាល សួរសុខទុក្ខអាជ្ញាធរមានសមត្ថកិច្ចកំពុងប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន និងពិនិត្យស្ថានភាពចេញ-ចូលរបស់ភ្ញៀវជាតិ អន្តរជាតិ និងប្រជាពលរដ្ឋ នៅច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន នៃស្រុក



គិរីវង់ ខេត្តតាកែវ នាព្រឹកថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២២។



-ជួបសំណេះសំណាល សួរសុខទុក្ខលោកស្រី នាងកញ្ញា ជាប្រធាន អនុប្រធាន និងសមាជិកាគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុកពញាឮ មកពីការិយាល័យជំនាញថ្នាក់ស្រុក និងឃុំទាំង១១ នៃស្រុកពញាឮ ព្រមទាំងឧបត្ថម្ភក្រមាចំនួន២៥ សារុងចំនួន២៥ ថ្នាំវីតាមីនសេចំនួន៣៨ប្រអប់ ម៉ាស់ចំនួន២៦ប្រអប់ និងថវិកាមួយចំនួន នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២។



❈នាថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ លោកជំទាវ **ទី ម្ញ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា និងក្រុមសមាជិកាព្រឹទ្ធសភា បានអញ្ជើញនាំយកទេយ្យទាន និងទេយ្យវត្ថុរួមមាន៖ អង្ករចំនួន២បាវ ត្រីខចំនួន១កេស ទឹកដោះគោខាប់ចំនួន១កេស មីចំនួន២កេសធំ ត្រីងៀតចំនួន៥គីឡូក្រាម ទឹកបរិសុទ្ធចំនួន៥កេស ទឹកក្រូចចំនួន៥កេស តែ ស្ករ នំខ្មែរ ផ្លែឈើ ព្រមទាំងចង្ហាន់ និងបច្ច័យមួយចំនួន ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៩ នៅវត្តមុនីប្រសិទ្ធិវង្ស ស្ថិតក្នុងខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។

❈នាថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំអំពីតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងការផ្ដល់សេវាធារណៈជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន នៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។




❈ឯកឧត្តម **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងលោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាខណ្ឌកំបូល និងមន្ត្រីពាក់ព័ន្ធដើម្បីស្ដាប់របាយការណ៍រួមក្នុងមូលដ្ឋាន ព្រមទាំងឧបត្ថម្ភនូវថវិកាមួយចំនួន ស្ថិតនៅសាលាខណ្ឌកំបូល រាជធានីភ្នំពេញ នាថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២២។

❈ឯកឧត្តម **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជាអធិបតីភាពក្នុងពិធីសុំម្ចាស់ទឹកម្ចាស់ដី និងប្រកាសបើកការដ្ឋានសាងសង់បណ្ណាល័យមួយខ្នងជូនសាលាបឋមសិក្សាបឹងក្អែក ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនសម្រាប់វេនបិណ្ឌនាពេលខាងមុខ និងអ្នកចូលរួមនៅភូមិបឹងក្អែក ឃុំពាមមានជ័យ ស្រុកពាមរក៍ ខេត្តព្រៃវែង នាថ្ងៃទី៨ ខែកញ្ញា

ឆ្នាំ២០២២។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់ និងស្ទឿន ដើម្បីស្តាប់របាយការណ៍រួមក្នុងមូលដ្ឋាន ព្រមទាំងឧបត្ថម្ភនូវថវិកាមួយចំនួន នៅសង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ នាថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់ស្នោរ និងសង្កាត់ឪឡោក ដើម្បីស្តាប់របាយការណ៍រួមក្នុងមូលដ្ឋាន ព្រមទាំងឧបត្ថម្ភនូវថវិកាមួយចំនួន នៅខណ្ឌកំបូល រាជធានីភ្នំពេញ នាថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល សួរសុខទុក្ខជាមួយប្រជាពលរដ្ឋតាមខ្នងផ្ទះដែលមានជីវភាពលំបាក និងចាស់ជរា នៅឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង នាព្រឹកថ្ងៃទី៣ និងថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២២។



-ដឹកនាំក្រុមសមាជិកាព្រឹទ្ធសភា នាំយកទេយ្យទាន និងទេយ្យវត្ថុ រួមមាន៖ អង្ករចំនួន២បាវ ត្រីខចំនួន១កេស ទឹកដោះគោខាប់ចំនួន១កេស មីចំនួន២កេសធំ ត្រីងៀតចំនួន៥គីឡូក្រាម ទឹកបរិសុទ្ធចំនួន៥កេស ទឹកក្រូចចំនួន៥កេស តែ ស្ករ-ស នំខ្មែរ ផ្លែឈើ ព្រមទាំងចង្ហាន់ និងបច្ច័យមួយចំនួន ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៩ នៅវត្តព្រៃកប្រាំង ក្នុងឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល នាថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២។

❈នាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា និងឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១ ដើម្បីឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធបុព្វការីជន ញាតិមិត្តជិតឆ្ងាយ កម្មាភិបាល យុទ្ធជន យុទ្ធនារី ដែលបានពលីជីវិតដើម្បីបុព្វហេតុជាតិមាតុភូមិ និងវេរភត្តាហារប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សា នៅវត្តបទុមវតី រាជធានីភ្នំពេញ។



❈នាថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចប្រធានព្រឹទ្ធសភា និងលោកជំទាវ ចែកជូនដល់ក្រុមប្រឹក្សាឃុំ និងបងប្អូនប្រជាពលរដ្ឋក្នុងឃុំត្រពាំងវែង ក្នុងម្នាក់ៗទទួលបាន៖ សម្លៀកបំពាក់១ឈុត សេរ៉ូមលាបមុខ១ប្រអប់ ម៉ាស់បិទមុខ២ប្រអប់ និងម្សៅទ្រនាប់លាបមុខ៥ប្រអប់ និងថវិកាមួយចំនួន ព្រមទាំងឧបត្ថម្ភថវិកាសម្រាប់ការរៀបចំអង្គពិធី និងបានចូលរួមរំលែកទុក្ខ និងចូលបច្ច័យបុណ្យសពប្រជាពលរដ្ឋមួយចំនួន នៅសាលាឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

❈ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ នៅឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី២៦ ខែសីហា និងថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៩ នៅសាលាបុណ្យ ស្ថិតក្នុងភូមិព្រៃឈើទាលលើ ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី១០ ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីសូត្រមន្តកាន់បិណ្ឌវេនទី១ នៅវត្តឥន្ទប្បត្តបុរី (ហៅវត្តអង្គរតូចខាងត្បូង) ស្ថិតក្នុងភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី១០ ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២។

❈ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ ព្រឹទ្ធសភាបានអញ្ជើញ៖

-ពិនិត្យការចាក់សាបបេតុង រែងដែកបន្ថែមនៅមុខទីស្នាក់ការប្រជាការពារឃុំ ដែលទើបនឹងសាងសង់រួចចំនួន ១២០ម៉ែត្រក្រឡា និងផ្ដល់សម្ភារផ្សេងៗសម្រាប់តុបតែងផ្ទៃក្នុង និងខាងក្រៅអគារ ព្រមទាំងបានជួបប្រជុំផ្ដាំផ្ញើដល់ប្រជាការពារទាំងអស់ចូលរួមថែទាំ និងប្រើប្រាស់ឱ្យបានគង់វង្សយូរអង្វែង នាថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១ នៅវត្តពោធារាម ព្រមទាំងចូលបច្ច័យមួយចំនួនកសាងឧបដ្ឋានសាលាបុណ្យ ដែលកំពុងសាងសង់ ស្ថិតក្នុងភូមិគគីរធំ ឃុំគគីរធំ ស្រុកគៀនស្វាយ ខេត្តកណ្ដាល នាថ្ងៃទី១០ ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២។

❈នាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **ចាន់ណារ៉េត** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបាន អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សា១ខ្នង មាន៥បន្ទប់ នៃសាលាបឋមសិក្សាប្រឡាយថ្ងរ និងផ្លូវក្រាលកៅស៊ូ ផ្លូវក្រាលគ្រួសក្រហម ផ្លូវលំជនបទ ព្រមទាំងសមិទ្ធផលនានា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅឃុំតាប៉ុន ស្រុកសង្កែ ខេត្តបាត់ដំបង។

❈នាថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **ម៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ នៃស្រុកគាស់ក្រឡ ខេត្តបាត់ដំបង។

❈ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៤ នៅវត្តកំពង់សិលា ស្ថិតក្នុងស្រុកកំពង់សិលា ខេត្តព្រះសីហនុ នាថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាភូមិ ឃុំ ស្រុក នាយប៉ុស្ដិ៍នគរបាលឃុំ ស្មៀន ស្ថិតក្នុងស្រុកគិរីសាគរ និងស្រុកកោះកុង ខេត្តកោះកុង នាថ្ងៃទី១៧ និងថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌទី១១ នៅវត្តឫស្សីជ្រុំ ព្រមទាំងជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ ស្រុក នាយប៉ុស្ដិ៍នគរបាលឃុំ ស្មៀន នៅស្រុកថ្មបាំង ខេត្តកោះកុង នាថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២។



❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងលោកជំទាវ **ម៉ុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចុះសួរសុខទុក្ខ ឯកឧត្តម **ផន ដាវី** សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ និងលោក **ព្រាប មុនី** ចៅសង្កាត់ព្រែកលៀប ដែលកំពុងសម្រាកព្យាបាល និងថែទាំសុខភាពនៅគេហដ្ឋាន ស្ថិតក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ នាថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការ

ទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ និងប្រធានភូមិទាំង១៣ ដើម្បីពិនិត្យលទ្ធផលការងារខែសីហា និងលើកទិសដៅការងារខែកញ្ញា ឆ្នាំ២០២២ ព្រមទាំងឧបត្ថម្ភថវិកាថែទាំសុខភាពមនុស្សចាស់ និងសម្ភារការិយាល័យមួយចំនួន នៅខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីសូត្រមន្តកាន់បិណ្ឌវេនទី១ នៅវត្តបទុមវតី រាជធានីភ្នំពេញ នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២។



-ជួបសំណេះសំណាល ព្រមទាំងឧបត្ថម្ភកន្សែងពោះគោជូនមន្ត្រីរាជការផ្នែកអនាម័យ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយក្ដីស្រឡាញ់ពេញចិត្ត និងលើកទឹកចិត្តលើការខិតខំបំពេញការងារ ដើម្បីលើកកម្ពស់គុណភាព សោភ័ណភាព និងបរិស្ថានបៃតងក្នុងបរិវេណព្រឹទ្ធសភា នាព្រឹកថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២។



-ចូលរួមវេទិកាសាធារណៈជាមួយនឹងក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ដើម្បីស្ដាប់ ទទួលសំណូមពរ និងរួមគ្នាដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ ដោយស្មារតីទទួលខុសត្រូវតាមភារកិច្ចរបស់ខ្លួន ស្ថិតក្នុងខណ្ឌទួលគោក រាជធានីភ្នំពេញ នារសៀលថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៤ នៅវត្តនាគវ័ន្ត ស្ថិតក្នុងសង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៧ នៅវត្តប្រជុំសាគរ (ហៅវត្តទឹកឃ្លាំង) ស្ថិតក្នុងស្រុកល្វាឯម ខេត្តកណ្ដាល នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២។

❈ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៦ នៅវត្តហរិរក្សរាជធានី (ហៅវត្តវាំងចាស់) ស្ថិតនៅឃុំវាំងចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យ និងនាំយកដង្វាយទៅថ្វាយ ដើម្បីសុំសេចក្តីសុខ សេចក្តីចម្រើន នៅបូជនីយដ្ឋានប្រវត្តិសាស្ត្រ លោកឧកញ៉ា **ឃ្លាំង មឿង** និងលោកជំទាវ **ខាន់ ខៀវ** នៅភូមិកំពែងស្វាយ ឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់ នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២។

-ជួបសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋតាមខ្នងផ្ទះ នៅភូមិក្តាន់រយ ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល នាព្រឹកថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២។

❈ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងសួរសុខទុក្ខគ្រួសារនៃសព នៅភូមិអង្គក្តួច ឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២។

-ជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនគ្រួសារក្រីក្រ គ្រួសារនៃសព៤គ្រួសារ រដ្ឋបាលឃុំ ប្រជាការពារ នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នារសៀលថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២២។

-ជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ និងសួរសុខទុក្ខប្រជាពលរដ្ឋនៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នារសៀលថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២។

❈ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ចុះសួរសុខទុក្ខ ឯកឧត្តម **ពូល នៅ** ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន ព្រមទាំងនាំយកអំណោយ និងថវិកាមួយចំនួន រួមមាន៖ ក្រូចពោធិ៍សាត់ចំនួន២ឡូ ទឹកដោះគោឆៅចំនួន២យួរ ទឹកសណ្តែកចំនួន៤យួរ ត្រីឆ្អើរចំនួន៣គីឡូក្រាម ថវិកាមួយចំនួន នៅភូមិចំការដូង សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១ នៅវត្តអង្គសិម្ពលី ស្ថិតនៅឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល នាព្រឹកថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមជាកិត្តិយសក្នុងពិធីបុណ្យ និងបូជាសពលោកស្រី **ហ៊ុន ឡាំង** គ្រូចូលនិវត្តន៍ នៅវត្តអង្គតាមិញ រាជធានី-



ភ្នំពេញ នារសៀលថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២។



-ចុះសួរសុខទុក្ខលោកជំទាវ **អ៊ឹម សាវឿន** អតីតអ្នកតំណាងរាស្ត្រខេត្តកំពង់ស្ពឺ បច្ចុប្បន្នជាទីប្រឹក្សារដ្ឋសភា នៅសង្កាត់សុព័រទេព ក្រុងច្បារមន ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២។



-ចុះសួរសុខទុក្ខលោកជំទាវ **ទឹម អ៊ីន** អតីតប្រធានមន្ទីរធម្មការ និងសាសនា ខេត្តកំពង់ស្ពឺ បច្ចុប្បន្នជាទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា នៅសង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យភ្ជុំបិណ្ឌនៅវត្តព្រៃពួច ស្ថិតនៅឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្តាល នាព្រឹកថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២។

❈ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែសីហា និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តតាកែវ នៅសាលា

ខេត្តតាកែវ នាថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១ នៅវត្តសីហរតនារាម ស្ថិតក្នុងក្រុងដូនកែវ ខេត្តតាកែវ នាថ្ងៃទី១០ ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី៧ នៅវត្តកោះអណ្តែត និងវត្តអង្គបុរាណមហារាជធម្មស្ថាន (ហៅវត្តប្រាសាទដែលទើបកសាងថ្មី) ស្ថិតក្នុងឃុំរមេញ ស្រុកកោះអណ្តែត ខេត្តតាកែវ នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២។

-នាំយកនូវទេយ្យទាន និងគ្រឿងឧបភោគ បរិភោគ វេរប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាក្នុងវត្តយុថិការ័ន្ត ស្ថិតក្នុងឃុំព្រៃយុថ្កា ស្រុកអង្គរបូរី ខេត្តតាកែវ នាថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២។

❈ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល ពិភាក្សាការងារក្រុមប្រឹក្សាឃុំឈ្នួលមានជ័យ ដើម្បីស្វែងយល់អំពីការងារផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ បញ្ហាប្រឈម និងសំណូមពរក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៥ នៅវត្តសុវណ្ណគិរីភ្នំជញ្ជាំង ស្ថិតក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២។

❈ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកកូនដើមឈើប្រភេទបេងអាហ្វ្រិកចំនួន៥០០ដើម ដែលជាអំណោយ ឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជូនដល់អង្គភាពអគ្គបញ្ជាការដ្ឋានរថក្រោះ



អគ្គបញ្ជាការប្រចាំទិសភូមិភាគទី៥ ស្ថិតនៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២។



-ចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីផែនការរួមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅសាលាខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២។



❈នាថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **ឆាយ វណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ដើម្បីស្តាប់នូវរបាយការណ៍អំពីការអភិវឌ្ឍមូលដ្ឋាន និងបញ្ហាប្រឈមនានា ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់ក្រុមប្រឹក្សាឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

❈នាថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **ឆាយ ថណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **សាយ ម៉ូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីសម្រេចស្តីពី ផែនការរួមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅខេត្តត្បូងឃ្មុំ។

❈ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីបុណ្យគម្រប់ខួប៧ថ្ងៃសពលោក **ណុប សី** ជំទប់ទី១ ឃុំព្រៃធំ នៅភូមិគគ្រួស ឃុំព្រៃធំ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយរដ្ឋបាលក្រុងស្វាយរៀង និងរដ្ឋបាលសង្កាត់ទាំង៧ របស់ក្រុង អំពីការអភិវឌ្ឍមូលដ្ឋាន ក្តីកង្វល់របស់ប្រជាពលរដ្ឋ និងការងារត្រៀមរៀបចំការបោះឆ្នោតសកលឆ្នាំ២០២៣ នៅក្រុងស្វាយរៀង ខេត្តស្វាយរៀង នាថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៧ នៅវត្តសន្តិភាព ស្ថិតនៅភូមិចុងព្រែក សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១០ នៅវត្តចំនួន៣គឺ៖វត្តព្រៃបឹស វត្តពោធិ៍ម្អម និងវត្តឯក (ហៅវត្តត្នោត) ស្ថិតនៅឃុំត្នោត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។

❈ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជាអធិបតីភាពក្នុងពិធីប្រគល់ចង្ក្រានសន្សំសំចៃ ថាមពលចំនួន៤០០ចង្ក្រាន ជាអំណោយរបស់ក្រុមហ៊ុន Guangzhou Iceberg Environmental Consulting Services Co., Ltd តាមរយៈលោកបណ្ឌិត **ជា មុនីឫទ្ធិ** ប្រធានសមាគមស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន ជូនប្រជាពលរដ្ឋនៅភូមិដូនច្រែង និងភូមិប៉ោយគៀង ឃុំព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៨-២៩ ខែសីហា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី៥ នៅវត្តសុវណ្ណគិរីភ្នំជញ្ជាំង ស្ថិតក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២។



-ចូលរួមជាមួយប្រធានទីប្រឹក្សាសមាគមខ្មែរ-ចិន លោក លោកស្រី សមាជិក សមាជិកាសមាគម និងនាយក នាយករង លោកគ្រូ អ្នកគ្រូ សាលាធីធឹង ដើម្បីស្តាប់ពីរបាយការណ៍ស្តីពី វឌ្ឍនភាពការងារ ចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈមរបស់សមាគម ស្ថិតនៅក្រុងសិរីសោភណ្ឌ ខេត្តបន្ទាយមានជ័យ នារសៀលថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២។



-ជាអធិបតីភាពក្នុងពិធីប្រគល់ពានរង្វាន់បាល់ទាត់មិត្តភាពអាយុ៣៥ឆ្នាំឡើង ចំនួន៤ខេត្ត រួមមាន៖ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប នារសៀលថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២។

❈ឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំពានរោង ព្រមទាំងឧបត្ថម្ភនូវអាវរងាក្នុងម្នាក់ចំនួន១អាវ និងថវិកាមួយចំនួន និងនាំយកទេយ្យវត្ថុ និងចង្ហាន់ទៅប្រគេនព្រះសង្ឃ ដែលគង់ចាំព្រះវស្សាវត្តព្រៃជ្រាំង ព្រមជាមួយនេះក៏បានប្រគេនស៊ីម៉ងត៍ចំនួន២តោន និងប្រគេនបច្ច័យសម្រាប់កសាងមួយចំនួន ស្ថិតនៅស្រុកស្វាយអន្ទរ ខេត្តព្រៃវែង នាព្រឹកថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២២។

-នាំយកទេយ្យវត្ថុ និងចង្ហាន់ ទៅប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សានៅវត្តក្របៅ ស្ថិតនៅឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង នាព្រឹកថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២។

❈ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមជាកិត្តិយសក្នុងពិធីជួបជុំក្រុមមិត្តល្អ ដើម្បីឈ្វេងយល់អំពីភូមិសាស្ត្រ ដែលសម្តេចតេជោនាយករដ្ឋមន្ត្រី ធ្វើការតស៊ូឆ្ពោះទៅដល់ការវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ស្ថិតនៅភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី២ នៅវត្តវិហារទន្ទឹម ស្ថិតនៅក្រុងសួង ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៦ នៅវត្តត្រពាំងព្រីង ស្ថិតនៅឃុំត្រពាំងព្រីង ស្រុកតំបែរ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៧ នៅវត្តភ្នំហាន់ជ័យ ស្ថិតនៅឃុំហាន់ជ័យ ស្រុកកំពង់សៀម ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២។

-ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែសីហា និងផ្សព្វផ្សាយសេចក្តីសម្រេចផែនការចូលរួមរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ព្រមទាំងនាំយកទេយ្យទាន ស៊ីម៉ងត៍១០តោន បច្ច័យកសាងមួយចំនួន និងបច្ច័យប្រគេនព្រះសង្ឃគង់នៅវត្តចង្វាបុប្ផារាម ស្ថិតនៅស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២។

❈នាថ្ងៃទី៤ ដល់ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ ២០២២ ឯកឧត្តម **ថុង ចន់** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ សង្កាត់ នៅសាលាក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

❈ឯកឧត្តម **ខឹម លាង** សមាជិកគណៈកម្មការទី១ ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំត្រពាំងគរ និងគណៈភូមិទាំង១០នៃឃុំត្រពាំងគរ គណៈគ្រប់គ្រងសាលាអនុវិទ្យាល័យស្អាង ប្រធានមណ្ឌលសុខភាព និងប៉ុស្តិ៍រដ្ឋបាលឃុំ ព្រមទាំងដោះស្រាយនូវបញ្ហាផ្សេងៗដែលមានក្នុងឃុំ ស្ថិតក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម នាថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០២២។

-ចូលរួមក្នុងពិធីបុណ្យសពឪពុកលោកអភិបាលស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២។

❈ឯកឧត្តម **ញ៉ូវ សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១ នៅវត្តនទីសេដ្ឋា ស្ថិតក្នុងឃុំស្បា ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ នាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៤ នៅវត្តចំនួន២ គឺវត្តសំរោងក្នុងឃុំសំរោង និងវត្តព្រៃខ្លុងក្នុងឃុំរកាត ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ព្រមទាំងបានចូលរួមរំលែកមរណ-ទុក្ខលោកស្រី **ម៉ៅ សេរី** ភរិយាលោក **សោម ទិសាល** ប្រធានក្រុមប្រឹក្សាស្រុកភ្នំក្រវាញដែលបានទទួលមរណ-ភាព នាថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមប្រជុំស្ដាប់របាយការណ៍របស់រដ្ឋបាលស្រុកភ្នំ-ក្រវាញ និងអបអរសាទរចំពោះក្រុមប្រឹក្សាឃុំដែលទើបតែចូលកាន់តំណែងថ្មី នៅស្រុកក្រវាញ ខេត្តពោធិ៍សាត់ នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌទី៧ នៅវត្តពោធិ៍សុវណ្ណ-រង្សី ឃុំអន្លង់វិល ស្រុកកណ្ដៀង និងថវិកាមួយចំនួនទៅបវរណាប្រគេនព្រះសង្ឃក្នុងវត្តព្នៅ ស្ថិតក្នុងឃុំស្នាមព្រះ ដើម្បីរួមចំណែកជាចង្ហាន់សម្រាប់កាន់បិណ្ឌទី៨ ព្រមទាំងមួយចំណែកសម្រាប់ព្រះសង្ឃប្រើប្រាស់ក្នុងការគង់ចាំព្រះ-វស្សា ស្ថិតក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២។

❈ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមបច្ច័យបុណ្យព្រមទាំងគោរពវិញ្ញាណក្ខន្ធព្រះ-សពទេមធម្មោ **ទិន គឹមហាន** ព្រះចៅអធិការវត្តព្រះអណ្ដូង នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២។

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពឧបាសក **ប្រាក់ ត្រាច** នៅភូមិពាមក្នុង ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់-ចាម ឆ្នាំ២០២២ នាល្ងាចថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមពិធីបុណ្យគម្រប់ខួប៧ថ្ងៃឧបាសក **ប្រាក់ ត្រាចំ** នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០២២។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធ-សភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខថ្នាក់ដឹកនាំសាស-និកឥស្លាម នៅភូមិកំពង់កែស ឃុំត្រពាំងសង្កែ នៅស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខថ្នាក់ដឹកនាំព្រះវិ-ហារឥស្លាម ព្រមទាំងចុះសួរសុខទុក្ខប្រជាពលរដ្ឋកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន នៅភូមិកំពង់កណ្ដាល សង្កាត់កំពង់កណ្ដាល ក្រុងកំពត ខេត្តកំពត នាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនប្រជាពលរដ្ឋដែលកំពុងសម្រាកព្យា-បាលជំងឺនៅគេហដ្ឋាន នៅភូមិម៉ាក់ប្រាង្គ ឃុំកំពង់ក្រែង ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋនៅភូមិទទឹងថ្ងៃ សង្កាត់បឹងទូក ក្រុងបូកគោ ខេត្តកំពត នាថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋនៅឃុំកំពង់ក្រែង និងឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខឯកឧត្តម **ឡា ឡៃ** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា នៅស្រុក-ស្រែអំបិល ខេត្តកោះកុង នាព្រឹកថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋចំនួន៣៥០នាក់ ព្រមទាំងចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិម៉ាក់ប្រាង្គ ឃុំកំពង់ក្រែង ស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋនៅភូមិថ្មី សង្កាត់ព្រៃធំ ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២។

❈នាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងលោកប្រធានភូមិ លោកលោកស្រី ជាសមាជិក សមាជិកាក្រុមប្រឹក្សាឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប។

❈នាថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **មួង ប៉យ** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សានៃស្រុកតាវែង ខេត្តរតនគិរី។

❈លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមកម្មវិធីបុណ្យខួបញោមព្រះមេគណខេត្តកំពង់-

ធំ ស្ថិតនៅវត្តឥន្ទ្រីយ៍សំវរៈ ហៅវត្តកំពង់ធំ ស្ថិតក្នុងក្រុងស្ទឹងសែន ខេត្តកំពង់ធំ នាថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២២។



-ជាអធិបតីភាពក្នុងពិធីបុណ្យផ្កាសាមគ្គីនៅវត្តក្រសាំង-មានជ័យ ស្ថិតនៅឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១ នៅវត្តឥន្ទប្បត្តបុរី (ហៅវត្តអង្គរតូចខាងត្បូង) ស្ថិតនៅភូមិក្រវ៉ាន់ សង្កាត់នគរ-ធំ ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីសូត្រមន្តបុណ្យកាន់បិណ្ឌវេនទី៥ ព្រម-ទាំងរាប់បាត្រ និងវេរភត្តប្រគេនព្រះសង្ឃជាកិច្ចបង្ហើយបុណ្យនៅវត្តកាលវ័ន្តក្តីចារ្ត៍ ភូមិទៀមចាស់ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសូត្រមន្តបុណ្យកាន់បិណ្ឌវេនទី៦ នៅវត្តកំពង់ស្វាយ ភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកកំពង់-ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៨ នៅវត្តឥន្ទ្រីសំវរៈ (ហៅវត្តកំពង់ធំ) ស្ថិតក្នុងសង្កាត់ព្រៃតាហ៊ូ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២។

❈នាថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ លោកជំទាវ **ខា ច័ន្ទទេវី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៤ ស្ថិតនៅវត្តទួលទំពូង សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានី-ភ្នំពេញ ។

❈នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំមានជ័យ ស្រុកសំឡូត ខេត្តបាត់ដំបង និងបានប្រគល់កុំព្យូទ័រមួយ-គ្រឿងដល់ប៉ុស្តិ៍រដ្ឋបាលឃុំមានជ័យ ស្ថិតនៅឃុំមានជ័យ ស្រុកសំឡូត ខេត្តបាត់ដំបង នាថ្ងៃទី២៤ ខែសីហា ឆ្នាំ ២០២២។

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពលោក **ម៉ែន ហាប់** ប្រធានក្រុមប្រឹក្សាក្រុងបាត់ដំបង នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង នាថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំសំឡូត និងប្រជាពលរដ្ឋមកពីឃុំស៊ុង ឃុំសំឡូត អំពីការងារកសិ-កម្មផ្តោតលើដំណាំយុទ្ធសាស្ត្រ និងដំណាំឆ្លងកាត់ (ដំណាំទុរេន ការប្រើប្រាស់ជី និងយុទ្ធសាស្ត្រទីផ្សារ រួមទាំងការវិចខ្ចប់ជាដើម) ស្ថិតនៅស្រុកសំឡូត ខេត្តបាត់ដំបង នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១០ នៅវត្តមុនី-ប្រសិទ្ធីវង្ស ស្ថិតនៅសង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជ-ធានីភ្នំពេញ នាថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២។

❈នាថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **ស្រី បេន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវ។

❈ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធ-សភាបានអញ្ជើញ៖

-ជួបសំណេះសំណាល សួរសុខទុក្ខក្រុមប្រឹក្សាឃុំផ្គាវ ឃុំអូរស្វាយ និងឃុំត្រពាំងប្រាសាទ ដើម្បីឈ្វេងយល់លើ



ការផ្តល់សេវាជូនប្រជាពលរដ្ឋ ការធ្វើអត្តសញ្ញាណប័ណ្ណ អត្រានុកូលដ្ឋាន ភូមិ ឃុំ មានសុវត្ថិភាព ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ និងបញ្ហាផ្សេងៗ ព្រមទាំងឧបត្ថម្ភម៉ាស់ សៀវភៅស្តីពីអំពើហិង្សាក្នុងគ្រួសារ និងថវិកាមួយចំនួន នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នាថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២២។



-ជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងបើកការដ្ឋានដាក់លូកាត់ទទឹងផ្លូវមួយកន្លែង ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន ស្ថិតក្នុងភូមិចេកក្បូរ ឃុំក្រសាំង ស្រុកចុងកាល ខេត្តឧត្តរមានជ័យ នាថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២២។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ដើម្បីឈ្វេងយល់លើការងារផ្តល់សេវាជូនប្រជាពលរដ្ឋ អត្រានុកូលដ្ឋាន ការធ្វើអត្តសញ្ញាណប័ណ្ណ ការងារភូមិ ឃុំ មានសុវត្ថិភាព និងឧបត្ថម្ភសៀវភៅស្តីពីអំពើហិង្សាក្នុងគ្រួសារ ម៉ាស់ និងថវិកាមួយចំនួន ស្ថិតក្នុងឃុំក្រសាំង ស្រុកចុងកាល ខេត្តឧត្តរមានជ័យ នាថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១ នៅវត្តឥន្ទប្បត្តបុរី (ហៅវត្តអង្គរតូចខាងត្បូង) ស្ថិតនៅភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី២ នៅវត្តព្រៃដង្ហើម ស្ថិតនៅឃុំកែវពណ៌ ស្រុកពួក ខេត្តសៀមរាប នាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៨ នៅវត្តផ្អាវ វត្តព្រៃស្អាត និងវត្តទំនប់ដាច់ ស្ថិតនៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នាថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២។

❋ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖




-ជួបសំណេះសំណាល សួរសុខទុក្ខក្រុមប្រឹក្សាឃុំកំពង់អុស ស្មៀនឃុំ ប្រធានប៉ុស្តិ៍រដ្ឋបាល និងប្រធានភូមិទាំង៥ ដើម្បីស្តាប់របាយការណ៍រួមក្នុងមូលដ្ឋាន ព្រមទាំងឧបត្ថម្ភ

ថវិកាមួយចំនួនដល់អ្នកចូលរួម និងសម្រាប់មូលនិធិសង្គហធម៌ឃុំ នៅសាលាឃុំកំពង់អុស ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២។



-ជាអធិបតីភាពក្នុងកិច្ចប្រជុំជាមួយក្រុមប្រឹក្សាស្រុក ឃុំ មេបញ្ជាការកងរាជអាវុធហត្ថ ដើម្បីពិនិត្យលទ្ធផលការងារខែសីហា និងលើកទិសដៅការងារខែកញ្ញា ឆ្នាំ២០២២ ពិសេសការបញ្ចូលទិន្នន័យសមាជិកតាមភូមិទូទាំងស្រុកក្នុងប្រព័ន្ធប្រៀបធៀបទិន្នន័យជំរឿនថ្មី ទៅនឹងទិន្នន័យកន្លងមក ព្រមទាំងជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ស្មៀនឃុំ ជំនួយការស្មៀន មេប៉ុស្ដិ៍នគរបាលរដ្ឋបាល គ្រូពេទ្យមណ្ឌលសុខភាព ប្រធានភូមិទាំង៥ ដើម្បីស្តាប់របាយការណ៍រួមក្នុងមូលដ្ឋាន និងឧបត្ថម្ភថវិកាមួយចំនួនសម្រាប់មូលនិធិសង្គហធម៌ឃុំ និងថវិកាជួសជុលផ្លូវ២ខ្សែ នៅសាលាស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៦ នៅវត្តទេពធីតារាម (ហៅវត្តយាយទេព) វត្តព្រះធាតុ និងវត្តបល្ល័ង្គ ស្ថិតក្នុងខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២។

❈ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖

-រៀបចំពិធីបុណ្យសង្ឃទាន រាប់បាត្រ ប្រគេនព្រះសង្ឃចំនួន១០វត្ត ក្នុងស្រុកដំណាក់ចង្អើរ នៅក្នុងបរិវេណសាលាស្រុកដំណាក់ចង្អើរ ខេត្តកែប នាថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៣ នៅវត្តឫស្សីស្ថិតក្នុងភូមិរបងក្រាស់ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត នាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៦ នៅវត្តគគីរជុំភ្នំខ្វាវ ស្ថិតក្នុងភូមិភ្នំលាវ ឃុំពងទឹក ស្រុក ដំណាក់ចង្អើរ ខេត្តកែប នាព្រឹកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៦ នៅវត្តវិបស្សនាធុរៈកែប និងវត្តសមុទ្ររង្សី ស្ថិតក្នុងភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប នារសៀលថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៨ នៅវត្តឫស្សីសាញ់ ស្ថិតក្នុងសង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២។

❈នាព្រឹកថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៨ នៅវត្តខេត្តវ៉ន ហៅវត្តទួលអង្គុញ និងវត្តសុវណ្ណារាម ហៅវត្តព្រៃទំនប់ ស្ថិតនៅឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។



❈នាព្រឹកថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **ញ៉ែម សាម៉ន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១ នៅវត្តឧទ្ធិស្សារាម (ហៅវត្តថាឡាបរិវ៉ាត់) ស្ថិតនៅឃុំថាឡាបរិវ៉ាត់ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

❈នាព្រឹកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២២ លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញនាំយកអង្ករចំនួន២បាវ និងថវិកាមួយចំនួនវេរប្រគេនដល់ព្រះសង្ឃគង់នៅវត្តព្រះឥន្ទកោសីយ៍ និងព្រះឥន្ទកោសា ស្ថិតនៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ



❋នាថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២២ សមាជិក សមាជិកាព្រឹទ្ធសភាចំនួន៩រូប បានអញ្ជើញចូលរួមស្តាប់បទបង្ហាញអំពីនីតិវិធីនៃការរៀបចំមហាសន្និបាតអាយប៉ាលើកទី៤៣ និងកិច្ចប្រជុំពាក់ព័ន្ធ នៅសាលសន្និសីទបាយ័ន នៃវិមានរដ្ឋសភា។




❋នាថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២២ សមាជិកព្រឹទ្ធសភាចំនួន៥រូប បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធ និងដាក់ឱ្យប្រើប្រាស់កីឡដ្ឋានខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅខេត្តកំពង់ស្ពឺ។

❋ឯកឧត្តម **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖



-ចុះសួរសុខទុក្ខ និងនាំយកមកនូវគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនជូនឧបាសិកា **ហាន្យ លឿន** មានជន្មាយុ ៧៩ឆ្នាំ នៅក្រុងសៀមរាប ខេត្តសៀមរាប នារសៀលថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០២២។



-ចុះសួរសុខទុក្ខ និងនាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួន ជូនឧបាសិកា **គ្រុយ ឆេង** ត្រូវជាម្តាយមីង ដែលមានជន្មាយុ៩៧ឆ្នាំ ស្ថិតនៅភូមិស្រង៉ែ ឃុំស្រង៉ែ ស្រុកព្រៃឈរ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២។



-ចូលរួមជាកិត្តិយសក្នុងពិធីបើកកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៤ និងកិច្ចប្រជុំពាក់ព័ន្ធ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានអាស៊ាន នៅខេត្តសៀមរាប នាថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២។

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ទទួលគណៈប្រតិភូដឹកនាំដោយឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងសហការីចុះមកបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់នៅ

តំបន់អភិវឌ្ឍន៍ម៉ុង ឫទ្ធី សែនជ័យ នៅភ្នំសែនជ័យ ស្រុកសំពោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២។

-ទទួលកញ្ញាបណ្ឌិត **ស៊ូវណ្ណា ហ្គោនឡែត** នាយិកាប្រតិបត្តិនៃអង្គការសម្ព័ន្ធមិត្តសត្វព្រៃ ព្រមទាំងសហការីអញ្ជើញចុះមកបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់អំពីហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍ ម៉ុង ឫទ្ធី សែនជ័យ នៅភ្នំសែនជ័យ ស្រុកសំពោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២២។

-ចូលរួមវេទិកាភាពជាអ្នកដឹកនាំ និងភាពជាដៃគូអាស៊ាន ឆ្នាំ២០២២ ក្រោមប្រធានបទ "ភាពជាដៃគូសម្រាប់អាស៊ានដែលមានភាពស្អិតរមួត និងឆ្លើយតបរហ័ស" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ Hyatt Regency រាជធានីភ្នំពេញ នាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២។

❋នាថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្ដម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្ដម **ឈិត គីមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីអបអរសាទរខួបលើកទី៧៧ បុណ្យជាតិវៀតណាម នៅសណ្ឋាគារ Sofitel Phokeethra Hotel រាជធានីភ្នំពេញ។



❋នាព្រឹកថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងពិធីបើកដំណើរការគម្រោងចែកចាយចង្ក្រានសន្សំសំចៃថាមពល និងធុងចម្រោះទឹកស្អាតដោយឥតគិតថ្លៃជូនដល់ប្រជាពលរដ្ឋ នៅសាលាខេត្តកំពត។

❋នាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ឯកឧត្ដម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ



ចូលរួមក្នុងពិធីបើកការដ្ឋានសាងសង់ស្ពានអាកាសចំណុចប្រសព្វមហាវិថី សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** មហាវិថីព្រះមុនីវង្ស វិថីកងយោធពលខេមរភូមិន្ទ និងស្ពានអាកាសចំណុចប្រសព្វមហាវិថីសហព័ន្ធរុស្ស៊ី និងមហាវិថីសម្ដេចចៅហ្វាវាំង វររៀងជ័យ អធិបតីស្រីង្គារ **គង់ សំអុល** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិព្រៃកន្ទួ១ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

❋ឯកឧត្ដម **ឈិត គីមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួម៖

-ប្រជុំតាមប្រព័ន្ធនិម្មិត (Virtual Meeting) រវាងរដ្ឋសភាកម្ពុជា ដឹកនាំដោយឯកឧត្ដមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១រដ្ឋសភា ជាមួយសមាគីសភាប្រជាជនចិនទូទាំងប្រទេស ដឹកនាំដោយឯកឧត្ដម **វ៉ាង ជិន** (Wang Chen) អនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ នៃសភាប្រជាជនចិនទូទាំងប្រទេស នៅសាលប្រជុំបាយ័ន នៃវិមានរដ្ឋសភា នាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២។

-ប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងអនុគណៈកម្មការខ្លឹមសារ និងឯកសារ នៃគណៈកម្មាធិការរៀបចំមហាសន្និបាតអន្តរសភាអាស៊ាន AIPA លើកទី៤៣ ក្រោមអធិបតីភាពឯកឧត្ដម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការទី៥រដ្ឋសភា នៅសាលប្រជុំបាយ័ន នៃវិមានរដ្ឋសភា នាថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២។

❋នាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ ឯកឧត្ដម **ឈិត គីមយាត** អនុប្រធាន និងឯកឧត្ដម **ឆាយ ចន្ទណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំត្រៀមរៀបចំមហាសន្និបាតអាយប៉ា (AIPA) លើកទី៤៣ និងកិច្ចប្រជុំរវាងប្រមុខដឹកនាំអាស៊ាន និង



ប្រធានសភាប្រទេសសមាជិកអាយប៉ា ASEAN-AIPA Interface Meeting ក្រោមអធិបតីភាពឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១រដ្ឋសភា នៅសាលប្រជុំបាយ័ន នៃវិមានរដ្ឋសភា។

❈នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការសង្គមកិច្ចសម្រាប់មហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៣ នៅសាលបន្ទាយស្រី នៃវិមានរដ្ឋសភា។

❈នាថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា ឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា និងឯកឧត្តម **ស្រី ចេន** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមបុណ្យសពម្ដាយក្មេកលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅភូមិគ្រឹះបុរីប៉េងហួត និងនាំសាររំលែកទុក្ខរបស់ឯកឧត្តមប្រធានគណៈកម្មការ ព្រមទាំងបច្ច័យរបស់គណៈកម្មការចូលបុណ្យ ស្ថិតនៅបុរីប៉េងហួតបឹងស្នោរ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

❈នាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ



ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់របស់គណៈកម្មាធិការស្ត្រីវ៉ាយប៉ា (WAIPA) ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** ប្រធានគណៈកម្មាធិការស្ត្រីវ៉ាយប៉ា និងជាអនុប្រធានទី២រដ្ឋសភា តាមប្រព័ន្ធនិម្មិត ដែលផ្សាយចេញពីវិមានរដ្ឋសភា។



❈នាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ លោកជំទាវ **ជា ច័ន្ទទេវី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រជុំគណៈកម្មាធិការសេដ្ឋកិច្ច នៃមហាសន្និបាតអន្តរសភាអាស៊ានអាយប៉ា (AIPA) លើកទី៤៣ ដើម្បីពិនិត្យខ្លឹមសារលើសេចក្ដីព្រាងសេចក្ដីសម្រេច និងឯកសារទស្សនាទាន ក្រោមអធិបតីភាពឯកឧត្តម **ឌី សុគន្ធ** ប្រធានប្រតិភូសភាកម្ពុជាសម្រាប់កិច្ចប្រជុំគណៈកម្មាធិការសេដ្ឋកិច្ច នៃមហាសន្និបាតអន្តរសភាអាស៊ានអាយប៉ា (AIPA) លើកទី៤៣ និងជាលេខាធិការគណៈកម្មការទី៥រដ្ឋសភា នៅសាលប្រជុំបន្ទាយស្រី នៃវិមានរដ្ឋសភា៕

## ការទទួលពាក្យបណ្ដឹង

❈នៅខែកញ្ញា ឆ្នាំ២០២២ ព្រឹទ្ធសភាបានទទួលពាក្យបណ្ដឹងចំនួន១ករណី បញ្ជូនពាក្យបណ្ដឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៣ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន៣ករណី កំពុងពិនិត្យសិក្សាចំនួន៣ករណី (សល់ពីខែមុន២ករណី) ឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន៣ករណី ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធ ចម្លងជូនគណៈកម្មការនានារបស់ព្រឹទ្ធសភាចំនួន៤ករណី៕

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារ ប្រចាំខែសីហា និងកំណត់ទិសដៅការងារខែកញ្ញា ឆ្នាំ២០២២




*ឯកឧត្តម អ៊ុំ សារឹទ្ធ (កណ្ដាល) ជាអធិបតីភាព*

នាព្រឹកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែសីហា និងលើកទិសដៅការងារសម្រាប់ខែកញ្ញា ឆ្នាំ២០២២ ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីអនុប្រធាននាយកដ្ឋានឡើង។

មានប្រសាសន៍បូកសរុបនាពេលនោះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** បានជម្រាបជូនអង្គប្រជុំបានជ្រាបអំពី សភាពការណ៍អន្តរជាតិ តំបន់ និងសភាពការណ៍ជាតិ ព្រមទាំងធ្វើការបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងខែសីហា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបន្ដយកចិត្តទុកដាក់យ៉ាងសកម្មលើមុខងារនីតិកម្ម ដោយបានរៀបចំ និងចាត់ចែងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងបើកសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៤ ព្រមទាំងការប្រជុំស្តីពី គម្រោងថវិកាឆ្នាំ២០២៣ របស់ព្រឹទ្ធសភា បានយ៉ាងល្អប្រសើរ។ ទន្ទឹមនឹងនោះ ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានអមដំណើរថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាចុះសួរសុខទុក្ខ និងនាំយកអំណោយថវិកាចែកជូនប្រជាពលរដ្ឋ ដែលមានជីវភាពខ្វះខាត និងបានជួបពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍមូលដ្ឋាន ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានាព្រមទាំងផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល ជាពិសេសណែនាំប្រជាពលរដ្ឋឱ្យទៅចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩(ដូសជំរុញ)ឱ្យបានគ្រប់ៗគ្នានៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា។

ចំពោះមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ ទទួលបានលទ្ធផលថ្មីៗបន្ថែមទៀត តាមរយៈការចុះ MOU ជាមួយនឹងសាធារណរដ្ឋកូរ៉េ និងចូលរួមកិច្ចប្រជុំ និងជួបពិភាក្សាការងារជាមួយគណៈប្រតិភូអន្តរជាតិនានា ស្របពេលដែលរាជរដ្ឋាភិបាលបានរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ានប្រកបដោយជោគជ័យដ៏ឧត្តុង្គឧត្តម និងសម្រេចបាននូវសេចក្ដីថ្លែងការណ៍រួមមួយក្នុងបរិបទដែលពិភពលោកកំពុងឡើងកម្ដៅខ្លាំង។ លទ្ធផលនេះ ស្ដែងចេញពីការអនុវត្តការទូតសភាដ៏ទន់ភ្លន់ជាជំហានដ៏សំខាន់ក្នុងការពង្រីកវិសាលភាព ដើម្បីជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីឱ្យបានកាន់តែល្អប្រសើរបន្ថែមទៀត។

សម្រាប់ខែកញ្ញាខាងមុខ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានណែនាំដល់អង្គភាពចំណុះទាំងអស់ត្រូវបន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពក្នុងការផ្ដល់សេវាឱ្យកាន់តែល្អប្រសើរ និងទាន់ពេលវេលាជូនដល់ថ្នាក់ដឹកនាំព្រឹទ្ធសភា ហើយថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទាំងអស់ ត្រូវបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការនានា ដែលរាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល បានដាក់ចេញជាពិសេសវិធានការ "៣ការពារ ៣កុំ" និងការចាក់វ៉ាក់សាំងដូសជំរុញឱ្យបានគ្រប់ៗគ្នាកុំបីខាន ដើម្បីការពារកុំឱ្យជំងឺកូវីដ-១៩អាចឆ្លងរាលដាលជាថ្មីទៀតបាន៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ ធុន គីមជី)



*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែសីហា*

# ថ្នាក់ដឹកនាំអង្គភាពចំណុះ អ.ពស ត្រូវបានពង្រឹងសមត្ថភាព លើជំនាញការគ្រប់គ្រងធនធានមនុស្ស



ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការព្រឹទ្ធសភា

នាព្រឹកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (អ.ពស) បានរៀបចំពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងធនធានមនុស្ស សម្រាប់ថ្នាក់ដឹកនាំគ្រប់អង្គភាពចាប់ពីអនុប្រធាននាយកដ្ឋានឡើងចំនួន ១១៣នាក់ ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។

មានប្រសាសន៍ក្នុងឱកាសបិទវគ្គបណ្តុះបណ្តាលនោះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** បានវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាជាសិក្ខាកាម ដែលបានចូលរួម និងឡើងមានមតិយោបល់យ៉ាងសកម្មដើម្បីចែករំលែកបទពិសោធន៍ បង្ហាញអំពីគំនិតថ្មីៗលើការទទួលខុសត្រូវ ឱ្យបានកាន់តែល្អប្រសើរឡើងថែមទៀត។

ឯកឧត្តម **អ៊ុំ សារឹទ្ធ** បានបញ្ជាក់ថា តាមរយៈវគ្គបណ្តុះបណ្តាលនេះ បានឆ្លុះបញ្ចាំងអំពីការអនុវត្តជាក់ស្តែងចាប់តាំងពីការបង្កើតព្រឹទ្ធសភាតាមដំណាក់កាល និងនីតិកាលនីមួយៗរហូតមកដល់ពេលបច្ចុប្បន្ន។ ការគ្រប់គ្រងមន្ត្រីបុគ្គលិកត្រូវផ្អែកលើទ្រឹស្តីឡើងតាមជម្រាល គឺឡើងពីតូចទៅធំ ឬពីមួយគន្លាក់ទៅមួយគន្លាក់ទើបមានមូលដ្ឋានគ្រឹះរឹងមាំដល់ការដឹកនាំគ្រប់គ្រង។ ជាមួយគ្នានេះ ការគ្រប់គ្រងមន្ត្រីបុគ្គលិកក៏ត្រូវគិតដល់ការសមភាពរវាងការប្រគល់ និងការទទួល រវាងអង្គភាព និងមន្ត្រីបុគ្គលិកផងដែរ។ ក្នុងន័យនេះ អង្គភាព ឬស្ថាប័នត្រូវផ្តល់ផលប្រយោជន៍ និងការលើកទឹកចិត្តដល់មន្ត្រីបុគ្គលិក។ ចំណែកឯមន្ត្រីបុគ្គលិកវិញត្រូវតបស្នងមកអង្គភាព ឬស្ថាប័នវិញតាមរយៈការបំពេញការងាររបស់ខ្លួនប្រកបដោយគុណភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

សូមជម្រាបថា វគ្គបណ្តុះបណ្តាលនោះ ប្រព្រឹត្តទៅក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា សិក្សារៀងរាល់ព្រឹកចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ ផ្តោតលើប្រធានបទសំខាន់ៗចំនួន ៨ រួមមាន៖

**១.ការគ្រប់គ្រងធនធានមនុស្សជាគន្លឹះឆ្ពោះទៅកាន់ជោគជ័យ**
**២.ការធ្វើផែនការធនធានមនុស្ស**
**៣.ការជ្រើសរើសមនុស្សប្រកបដោយប្រសិទ្ធភាព**
**៤.ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស**
**៥.ប្រសិទ្ធភាព នៃការបំពេញការងាររបស់បុគ្គលិក**
**៦.ការលើកទឹកចិត្តបុគ្គលិក (ប្រាក់កម្រៃ ការលើកទឹកចិត្ត និងអត្ថប្រយោជន៍)**
**៧.ទំនាក់ទំនងការងាររវាងស្ថាប័ន និងបុគ្គលិក**
**៨.ធានាបរិស្ថានការងារប្រកបដោយសុវត្ថិភាព សុខុមាលភាព និងសុខភាព៕**

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ ធុន គីមជី)



ថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចូលរួមបិទវគ្គបណ្តុះបណ្តាល

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភារៀបចំពិធីបរិច្ចាគឈាម




*ឯកឧត្តម អ៊ុំ សារឹទ្ធ និងលោកវេជ្ជបណ្ឌិត លី សុវិទ្យ*

នាព្រឹកថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ នៅវិមានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសហការជាមួយនឹងមជ្ឈមណ្ឌលជាតិផ្ដល់ឈាម បានរៀបចំពិធីបរិច្ចាគឈាម ដើម្បីជួយសង្គ្រោះជីវិតមនុស្សក្រោមប្រធានបទ៖ ខ្ញុំ និងអ្នក យើងទាំងអស់គ្នារួមគ្នាលើកកម្ពស់វប្បធម៌ផ្ដល់ឈាមសង្គ្រោះជីវិត ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បុគ្គលិកវិមាន ៧មករា និងយុវជន ស.ស.យ.ក ខណ្ឌជ្រោយចង្វារ ដែលជាអ្នកស្ម័គ្រចិត្តបរិច្ចាគឈាម។

មានប្រសាសន៍ក្នុងឱកាសនោះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានថ្លែងនូវការកោតសរសើរ




*ឯកឧត្តម អ៊ុំ សារឹទ្ធ មានប្រសាសន៍ក្នុងអង្គពិធី*

ដល់ក្រុមការងារពាក់ព័ន្ធដែលបានសហការគ្នារៀបចំឱ្យមានកម្មវិធីនេះឡើង ព្រមទាំងបានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បុគ្គលិកវិមាន៧មករា និងសមាជិក សមាជិកានៃសហភាពសហព័ន្ធយុវជនកម្ពុជាខណ្ឌជ្រោយចង្វារ ព្រមទាំងអ្នកស្ម័គ្រចិត្តទាំងអស់ដែលបានចូលរួមផ្ដល់ឈាម។

ឯកឧត្តម **អ៊ុំ សារឹទ្ធ** បានបញ្ជាក់ថា កម្មវិធីបរិច្ចាគឈាមនៅពេលនេះ មានគោលបំណងសំខាន់ពីរគឺ ទី១-ធ្វើអំណោយឈាមជូនមជ្ឈមណ្ឌលជាតិផ្ដល់ឈាម ដើម្បីយកទៅប្រើប្រាស់ក្នុងការជួយសង្គ្រោះជីវិតមនុស្ស ទី២-ចូលរួមផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការបរិច្ចាគឈាម និងចូលរួមលើកកម្ពស់វប្បធម៌នៃការធ្វើអំណោយឈាម។ ឯកឧត្តមសង្ឃឹមថា ការបរិច្ចាគឈាមនឹងក្លាយជាកិច្ចការមនុស្សធម៌មួយដ៏សំខាន់ក្នុងការជួយសង្គ្រោះជីវិតមនុស្ស។

ឯកឧត្តម **អ៊ុំ សារឹទ្ធ** បានសង្កត់ធ្ងន់ថា ឈាមជាអំណោយដ៏មានតម្លៃមិនអាចមានអ្វីមកប្រៀបបានឡើយ។ វិទ្យាសាស្ត្រមិនទាន់អាចផលិតឈាមបាននោះទេ ដូច្នេះហើយ យើងត្រូវការជាចាំបាច់នូវការធ្វើអំណោយឈាមពីសប្បុរសជន ដើម្បីជួយសង្គ្រោះអាយុជីវិតជនរងគ្រោះដែលត្រូវការឈាម។ ការធ្វើអំណោយឈាម មិនត្រឹមតែជាការប្រោសជីវិតជនរងគ្រោះដែលត្រូវការការឈាមប៉ុណ្ណោះទេ តែក៏ជាការប្រោសឱ្យមានក្ដីសង្ឃឹម និងស្នាមញញឹមសម្រាប់ក្រុមគ្រួសារជនរងគ្រោះទាំងមូលឱ្យរួចផុតពីទុក្ខនៃការបាត់បង់សមាជិកក្រុមគ្រួសារខ្លួន។ ជាងនេះទៀត ការផ្ដល់ឈាម ក៏ជាការជួយសង្គ្រោះធនធានមនុស្សជាតិយើងផងដែរ។ ក្នុងន័យនេះ ឯកឧត្តមបានលើកទឹកចិត្តមន្ត្រីបុគ្គលិក ជាពិសេសយុវជនយើងទាំងអស់ ចូលរួមឱ្យកាន់តែសកម្មថែមទៀតក្នុងការធ្វើអំណោយឈាមដោយសុវត្ថិភាព ស្រប



*ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមក្នុងពិធីផ្តល់ឈាម*





តាមការណែនាំរបស់មជ្ឈមណ្ឌលជាតិផ្តល់ឈាម។ បើតាមលោកវេជ្ជបណ្ឌិត **លី សុទិឡ** អនុប្រធានមជ្ឈមណ្ឌលជាតិផ្តល់ឈាមបានឱ្យដឹងថា ការបរិច្ចាគឈាមមានអត្ថប្រយោជន៍ច្រើនសម្រាប់សុខភាព ដូចជា៖ ការបរិច្ចាគឈាមម្តងមានចំនួនក្រើនរំលឹកសុខភាពម្តង ដឹងពីស្ថានភាពជំងឺផ្សេងៗដូចជា៖ ជំងឺថ្លើមប្រភេទB ប្រភេទC ស្វាយ អេដស៍។ល។ ជួយកាត់បន្ថយជំងឺមហារីកនានា កាត់បន្ថយកំហាប់ក្នុងឈាម ការលើសជាតិដែក ដែលធ្វើឱ្យមានផលប៉ះពាល់ដល់ថ្លើម និងលំពែង ជួយធ្វើឱ្យប្រសើរឡើងនូវសុខភាពបេះដូង កាត់បន្ថយការឡើងទម្ងន់ ជំងឺដាច់សរសៃឈាមក្នុងខួរក្បាលជាដើម៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ ធុន គីមជី)





*ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមក្នុងពិធីផ្តល់ឈាម*

## សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា និងជាអនុប្រធានទី១ នៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង (ASGPF) បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង (ASGPF) ក្រោមអធិបតីភាព ឯកឧត្តម Najib El Khadi អគ្គលេខាធិការរដ្ឋសភាម៉ារ៉ុក និងជាប្រធានស្ដីទី នៅរដ្ឋសភា នៃព្រះរាជាណាចក្រម៉ារ៉ុក។





❈នាថ្ងៃទី២ ទី៣ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា និងជាអនុប្រធានទី១ នៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង (ASGPF) បានអញ្ជើញចូលរួមក្នុងពិធីបើកមហាសន្និបាត នៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង (ASGPF) ក្រោមអធិបតីភាពឯកឧត្តម Najib El Khadi អគ្គលេខាធិការរដ្ឋសភាម៉ារ៉ុក និងជាប្រធានស្ដីទី (ASGPF) នៅរដ្ឋសភា នៃព្រះរាជាណាចក្រម៉ារ៉ុក ដោយមានសមាសភាពអញ្ជើញចូលរួមមកពីបណ្ដាប្រទេសប្រើភាសាបារាំងសរុបចំនួន៥៤រូប។





❈នាព្រឹកថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង១០:០០នាទី ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅអគ្គលេខាធិការដ្ឋានសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដឹកនាំដោយឯកឧត្តម **សយ កុសល** ប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ (សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន) នៅសាលប្រជុំពិសេស វិមានព្រឹទ្ធសភា។





# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នារសៀលថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការស្ដីទីព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្ដុះបណ្ដាលស្ដីពី ការប្រាស្រ័យឆ្លើយឆ្លងគោលនយោបាយសាធារណៈ តាមប្រព័ន្ធនិម្មិត (ZOOM) នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។






❈នារសៀលថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការស្ដីទីព្រឹទ្ធសភា និងលោកស្រីឧត្ដមសេនីយ៍ទោ **មុំ សាឃន** អនុប្រធាននាយកដ្ឋានអង្គរក្ស នៃអគ្គស្នងការនគរបាលជាតិ នៃក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្ដុះបណ្ដាលស្ដីពី ជំនាញការពារថ្នាក់ដឹកនាំ របៀបប្រើប្រាស់ខ្លោងទ្វារសុវត្ថិភាព និងបច្ចេកទេសម៉ាស៊ីន X-Ray នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។






❈នាព្រឹកថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃប្រទេសបារាំងនៅកម្ពុជា ចុះទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋក្រីក្រដោយឥតគិតថ្លៃ នៅសាលាបឋមសិក្សាវត្តខ្វរ ស្ថិតក្នុងសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។





## សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **ឈឹម ព្រះខ័ន** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុប្រចាំខែសីហា ឆ្នាំ២០២២ និងពិនិត្យវាយតម្លៃលើវគ្គបណ្ដុះបណ្ដាលស្ដីពី ការគ្រប់គ្រងធានធានមនុស្ស នៅសាលសិក្ខាសាលាខាងជើង ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុចាប់ពីអនុប្រធាននាយកដ្ឋានឡើង។



❈នាថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **កែវ ចាន់ណា** អគ្គនាយក នៃអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ បានអញ្ជើញចូលរួមវេទិកា ស្ដីពីរដ្ឋាភិបាលឌីជីថលកម្ពុជា-កូរ៉េ ក្រោមអធិបតីភាព ឯកឧត្តម **ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៅសណ្ឋាគារហៃយ៉ាត់ រីជីនស៊ី រាជធានីភ្នំពេញ។



❈នារសៀលថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយរបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** និងលោកជំទាវ ជូនប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រខ្វះខាតចំនួន៣៥ គ្រួសារ នៅភូមិកណ្ដាលកោះ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។



❈នាព្រឹកថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ ប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣៥រូប ដឹកនាំដោយលោកស្រី **ឃុន សុវណ្ណនេត្រា** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញបំពេញទស្សនកិច្ចឈ្វេងយល់ភូមិគំរូមិត្តភាពចិន-កម្ពុជា ស្ថិតក្នុងភូមិតានន ឃុំដូង ស្រុកបាទី ខេត្តតាកែវ៕



